MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT



# សៀវភៅមគ្គុទេសក៍ ស្តីពីការបញ្ជ្រាបយេនឌ័រ នៅក្នុងសកម្មភាព និងមុខងារស្នូលរបស់ គណៈកម្មការទន្លេមេគង្គ

សៀវភៅណែនាំសម្រាប់អាងទន្លេមេគង្គក្រោមដែលមានភាពធន់
និងឆ្លើយតបនឹងយេនឌ័រ

# សៀវភៅមគ្គុទេសក៍ស្ដីពីការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាព និងមុខងារស្នូលរបស់គណៈកម្មការទន្លេមេគង្គ

*សៀវភៅណែនាំសម្រាប់អាងទន្លេមេគង្គក្រោមដែលមានភាពធន់ និងឆ្លើយតបនឹងយេនឌ័រ*

ធ្នូ ២០២២

*គណៈកម្មការទន្លេមេគង្គ ត្រូវបានគាំទ្រវិភាគទានដោយប្រទេសជាសមាជិក និងដៃគូអភិវឌ្ឍន៍ រួមមាន ប្រទេសអូស្ត្រាលី សហភាពអឺរ៉ុប ប្រទេសហ្វាំងឡង់ ផ្លែនដឺរស៍/បែលហ្សិក បារាំង អាល្លឺម៉ង់ ជប៉ុន លុចសំបួរ ហូឡង់ នូវែលសេឡង់ ស៊ុយអែត ស្វីស និងសហរដ្ឋអាមេរិក។*

**រក្សាសិទ្ធិ @ គណៈកម្មការទន្លេមេគង្គ ២០២២**
បោះពុម្ពផ្សាយលើកទី១ (២០២២)

រក្សាសិទ្ធិខ្លះៗ

ស្នាដៃនេះ គឺជាសមិទ្ធផលមួយរបស់លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ។ ទោះបីជាមានការព្យាយាមបង្ហាញព័ត៌មានដ៏សុក្រិតយ៉ាងណាក្តី គណៈកម្មការទន្លេមេគង្គមិនធានាពីសុក្រិតភាពនៃទិន្នន័យដែលបានដាក់បញ្ចូលទៅក្នុងសមិទ្ធផលនេះទេ។ ការបង្ហាញព័ត៌មានពីព្រំប្រទល់ ពណ៌ និង ការកំណត់ទីតាំងផែនទីណាមួយនៅក្នុងឯកសារនេះមិនមែនជាការវិនិច្ឆ័យរបស់គណៈកម្មការទន្លេមេគង្គ ទាក់ទងនឹងស្ថានភាពផ្លូវច្បាប់របស់ប្រទេស ឬការយល់ព្រម ឬការទទួលស្គាល់ព្រំដែនបែបណាមួយនោះទេ។

គ្មានចំណុចណាមួយនៅទីនេះតំណាងឲ្យ ឬចាត់ទុកជាការដាក់កំហិត ឬលះបង់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃគណៈកម្មការទន្លេមេគង្គ ដែលត្រូវបានរក្សាជាពិសេសនោះទេ។

ការបោះពុម្ពផ្សាយទាំងមូល ឬផ្នែកណាមួយនៃឯកសារនេះសារជាថ្មី និងក្នុងទម្រង់ណាមួយដែលជាប្រយោជន៍ដល់ការសិក្សា ឬដោយគោលបំណងមិនស្វែងរកប្រាក់ចំណេញ មិនចាំបាច់មានការអនុញ្ញាត្តិជាពិសេសពីអ្នករក្សាសិទ្ធិទេ ប្រសិនបើអ្នកប្រើប្រាស់ទទួលស្គាល់ប្រភពដើម និងជូនដំណឹងទៅកាន់គណៈកម្មការទន្លេមេគង្គ។ លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ មានសេចក្តីសោមនស្សនឹងទទួលយកច្បាប់ចម្លងរាល់ការបោះពុម្ពផ្សាយទាំងឡាយណាដែលប្រើប្រាស់ឯកសារនេះជាឯកសារយោង។ ការបោះពុម្ពផ្សាយនេះមិនអាចប្រើប្រាស់សម្រាប់លក់ ឬក្នុងគោលបំណងពាណិជ្ជកម្ម ដោយគ្មានការអនុញ្ញាត្តិជាលាយលក្ខិអក្សរពីលេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គទេ។

**ចំណងជើង៖** សៀវភៅមគ្គុទេសក៍ស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាព និងមុខងារស្នូលរបស់គណៈកម្មការទន្លេមេគង្គ៖ សៀវភៅណែនាំសម្រាប់អាងទន្លេមេគង្គក្រោមដែលមានភាពធន់ និងឆ្លើយតបនឹងយេនឌ័រ

Doi:https://doi.org/10.52107/mrc.bkbwir

**ពាក្យគន្លឹះ៖** ការបញ្ជ្រាបយេនឌ័រ/ សៀវភៅណែនាំស្តីយេនឌ័រ/គណៈកម្មការទន្លេមេគង្គ/អាងទន្លេមេគង្គក្រោម

សម្រាប់ឯកសារយោង ឯកសារនេះអាចនឹងត្រូវបានដកស្រង់ដូចខាងក្រោម៖
គណៈកម្មការទន្លេមេគង្គ។ (២០២២)។ *សៀវភៅមគ្គុទេសក៍ស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាព និងមុខងារស្នូលរបស់គណៈកម្មការទន្លេមេគង្គ៖ សៀវភៅណែនាំសម្រាប់អាងទន្លេមេគង្គក្រោមដែលមានភាពធន់ និងឆ្លើយតបនឹងយេនឌ័រ*។ វៀងចន្ទ៖ លេខធិករដ្ឋ នៃនគណៈកម្មករទេន្លមេគង្គ។

DOI: https://doi.org/10.52107/mrc.bkbwir

លោកអ្នកអាចរកព័ត៌មានពីឯកសារបោះពុម្ពផ្សាយ និងឯកសារឌីជីថលរបស់គណៈកម្មការទន្លេមេគង្គ តាមរយៈ

គេហទំព័រ http://www.mrcmekong.org/publications
**រាល់សំណួរទាក់ទិននឹងសិទ្ធិ និងអាជ្ញាប័ណ្ណ អាចផ្ញើរទៅ៖**
គណៈកម្មការទន្លេមេគង្គ
មជ្ឈមណ្ឌលសិក្សា និងឯកសារ
ផ្លូវ១៨៤ ហ្វាងុំ ប្រអប់សំបុត្រលេខ៦១០១ ទីក្រុងវៀងច័ន្ទ ប្រទេសឡាវ
ទូរស័ព្ទ៖ +៨៥៦ ២១ ២៦៣២៦៣ | អ៊ីម៉ែល៖ mrcs@mrcmekong.org | គេហទំព័រ៖
www.mrcmekong.org

## ការដកស្រង់

គណៈកម្មការទន្លេមេគង្គ។ (២០២២)។ *សៀវភៅមគ្គុទេសក៍ស្ដីពីការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាព និងមុខងារស្នូលរបស់គណៈកម្មការទន្លេមេគង្គ៖ សៀវភៅណែនាំសម្រាប់អាងទន្លេមេគង្គក្រោមដែលមានភាពធន់ និងឆ្លើយតបនឹងយេនឌ័រ*។ វៀងចន្ទ៖ លេខធិការដ្ឋ នៃនគណៈកម្មការទេន្លមេគង្គ។

DOI: https://doi.org/10.52107/mrc.bkbwir

## អ្នកនិពន្ធ

**ការគ្រប់គ្រង**

លោក សានទិ បារ៉ា ន់ (Santi Barann) ប្រធានផ្នែកយុទ្ធសាស្ត្រ និងភាពជាដៃគូ

**មន្ត្រីជំនាញបច្ចេកទេសរបស់លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ**

លោក សុភ័ក្រ មាស (Sopheak Meas) មន្ត្រីជំនាញផ្នែកភាគីពាក់ព័ន្ធ

**មន្ត្រីជំនាញអន្តរជាតិ**

លោកស្រី សានដ្រា បូដេ (Sandra Bode) មន្ត្រីជំនាញផ្នែកយេនឌ័រ និងភាពងាយរងគ្រោះ

# អារម្ភកថា

ដូចយើងតែងតែលើកឡើងថា ទន្លេមេគង្គ "ជារបស់យើងទាំងអស់គ្នា"។ នេះមានន័យថា យើងម្នាក់ៗ គប្បីមានស្មារតីជាម្ចាស់ និងការទទួលខុសត្រូវលើ និងថែគាំពារមេធ្យោបាយផ្លូវទឹកមួយនេះ ដែលជាសសៃឈាមនៃតំបន់អាស៊ីអាគ្នេយ៍ ដោយមិនគិតពីសញ្ជាតិ ជាតិសាសន៍ សាសនា ឬយេនឌ័រឡើយ។

នេះក៏មានន័យផងដែរថា យើងមិនត្រឹមតែមានសិទ្ធិទទួលផលប្រយោជន៍ដោយសមធម៌ ពីការអភិវឌ្ឍធនធានទន្លេនេះប៉ុណ្ណោះទេ ក៏ប៉ុន្តែមិនមានប្រជាជនក្រុមណា ឬសហគមន៍ណាមួយ រងការលំបាកដោយអសមាមាត្រឡើយ បើទោះបីជាដោយសារបុព្វហេតុនៃការអភិវឌ្ឍដូចគ្នា ឬផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ នៅក្នុងទម្រង់នៃគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ដែលកាន់តែធ្ងន់ធ្ងរក៏ដោយ។

នៅឯគណៈកម្មការទន្លេមេគង្គ យើងធ្វើការពាក់ព័ន្ធនឹងគ្រប់ផ្នែកទាំងអស់នៃវិស័យទឹក រួមទាំងបញ្ហាសមភាពផងដែរ។ ដូចអ្វីដែលយើងជឿជាក់ បុគ្គលគ្រប់រូប គប្បីទទួលបានការប្រើប្រាស់ទឹកដោយស្មើភាពគ្នា យើងក៏ត្រូវការទទួលបានព័ត៌មានដោយសមភាពពីទឹកផងដែរ។

បើទោះជាយ៉ាងនេះក្ដី អស់រយៈកាលយ៉ាងយូរដែលយើងមិនបានអនុវត្តឲ្យបានគ្រប់គ្រាន់ ក្នុងការធានាថាស្ត្រីនៅអាងទន្លេមេគង្គក្រោមទទួលបានទាំងទឹក និងព័ត៌មានពាក់ព័ន្ធដោយស្មើភាពគ្នា។ បើទោះជាយើងមិនពិចារណាលើកត្តានេះក្ដី វាមិនមានន័យថា វាអវត្តមានវិសមភាព ភាពអយុត្តិធម៌ ឬទុរគតភាពសម្រាប់ស្ត្រីនោះទេ។ ផ្ទុយមកវិញ វាអាចបង្កឲ្យមានភាពងាយរងគ្រោះកាន់តែខ្លាំងសម្រាប់ពួកគេ។

តួយ៉ាងនៅអំឡុងពេលមានគ្រោះអន្តរាយមួយ ស្ត្រី និងបុរសអាចនឹងប្រឈមនឹងហានិភ័យនេះ ដោយមានកម្រិតផ្សេងៗគ្នានៃភាពងាយរងគ្រោះ។ ស្ត្រីអាចខកខាន មិនបានទទួលការជូនដំណឹងជាមុន ដោយសារតាំងពីបុរាណមក ពួកគេនៅផ្ទះ ថែរក្សាសមាជិកក្រុមគ្រួសារគេ។ កត្តានេះ អាចនឹងកាត់បន្ថយការត្រៀមខ្លួនទប់ទល់នឹងហានិភ័យ និងពេលវេលាឆ្លើយតប តែវាបង្កើនឲ្យមានឱកាសផ្សេងៗនៃការរងគ្រោះ។

ទោះជាយ៉ាងណា បើយើងមើលផ្ទុយមកវិញ សមភាពយេនឌ័រ មានកម្រិតលើសពីការកាត់បន្ថយភាពងាយរងគ្រោះ នៅពេលដែលបញ្ហាប្រឈមនានា បានកើនឡើង។ យើងសង្ឃឹមថា វាក៏សំដៅលើភាពធន់កាន់តែខ្លាំងឡើងផងដែរ។ ចំណុចនេះ ជួយបកស្រាយពីកត្តាជំរុញក្នុងការបង្កើតសៀវភៅនេះ ដែលមានចំណងជើងថា *សៀវភៅមគ្គុទេសក៍*ដំបូងបំផុតរបស់ MRC ស្ដីពី*ការបញ្ជ្រាបយេនឌ័រ*។

ប្រាកដណាស់ សៀវភៅមគ្គុទេសក៍នេះ មិនសំដៅសម្រាប់អ្នកអានជាទូទៅនោះទេ។ ផ្ទុយមកវិញ វាជាឧបករណ៍បច្ចេកទេសដ៏សំខាន់ សម្រាប់បុគ្គលិកនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ក៏ដូចជាសម្រាប់ប្រទេសជាសមាជិកទាំងបួន និងទីភ្នាក់ងារបណ្ដាញរបស់បណ្ដាលប្រទេសទាំងនេះ ដើម្បីធានាថាយេនឌ័រត្រូវបានគេពិចារណាដោយយកចិត្តទុកដាក់បំផុត ក្នុងអំឡុងពេលបំពេញតួនាទី និងសកម្មភាពផ្សេងៗ។ នេះមានន័យថា សៀវភៅនេះក៏មាននៅតាមបណ្ដាលស្ថាប័នផ្សេងៗផងដែរ ដែលស្វែងរក

ការណែនាំពីរបៀបដាក់បញ្ជ្រាបយេនឌ័រអោយកាន់តែមានបរិយាបន្នទៅក្នុងយុទ្ធសាស្ត្រ និងគម្រោងរបស់ស្ថាប័ន ព្រោះវាបានផ្តល់នូវបញ្ជីរសំណួរសំខាន់ៗសម្រាប់ធ្វើការពិចារណា។

បើនិយាយអោយកាន់តែទូលំទូលាយ យើងទទួលស្គាល់ថា បច្ចុប្បន្ននេះ ព្រឹត្តិការណ៍សមភាពយេនឌ័រកំពុងនឹងកើនឡើង ដោយហេតុថា បញ្ហានេះផ្ទាល់បានក្លាយជាបញ្ហាធម្មតាដែលកើតមានឡើងជាទូទៅ។ ការទទួលបានទឹក និងសមភាពយេនឌ័រ តាងឲ្យគោលដៅចំនួនពីរក្នុងចំណោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង១៧។ សម្រាប់បណ្តាលប្រទេសជាសមាជិកទាំងបួន ក៏ដូចជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា អាស៊ាន) ការបញ្ជ្រាបយេនឌ័រ បានក្លាយជាអាទិភាពគោលនយោបាយមួយរួចទៅហើយ។

ទន្ទឹមនឹងនេះផងដែរ MRC ទទួលស្គាល់ពីគម្លាតនានាដែលមាននៅក្នុងទិន្នន័យរបស់ខ្លួន ព្រោះថាការពីមុនៗ យើងមិនបានប្រមូលព័ត៌មានតាមផ្នែកយេនឌ័រ ឬបានត្រិះរិះពីការចូលរួមប្រកបដោយអត្ថន័យពីស្ត្រីនោះទេ ពេលដែលយើងរៀបចំផែនការយុទ្ធសាស្ត្រ ឬគម្រោងថ្មីៗ។ យើងកំពុងធ្វើការកែលម្អបញ្ហានេះ។

ការពិចារណាពីការបញ្ជ្រាបយេនឌ័រ គប្បីអនុវត្តឡើងដោយដាក់ទាំងស្ត្រី និងបុរស និងស្ថានភាពងាយរងគ្រោះជាក់លាក់ ឬដោយឡែករបស់ពួកគេ ជាចំណុចស្នូលនៃសកម្មភាពនានារបស់យើង ដើម្បីផ្តល់លទ្ធភាពឲ្យអន្តរាគមន៍ណាមួយរបស់ MRC ជួយគាំទ្រដោយផ្ទាល់ ឬជួយផ្តល់ប្រយោជន៍ដល់ភាគីទាំងពីរបាន។

នៅពេលដែលយើងបន្ថែមកិច្ចខិតខំប្រឹងប្រែងលើសមភាពឲ្យកាន់តែខ្លាំង យើងសង្ឃឹមថា ការបញ្ជ្រាបយេនឌ័រ នឹងមិនត្រឹមតែធ្វើឲ្យទន្លេមេគង្គក្លាយជាតំបន់ដែលមានបរិយាបន្នខ្លាំងប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងធ្វើឲ្យតំបន់នេះកាន់តែមានភាពធន់ផងដែរ។

**អានុល័ក គិធិឃួន**
នាយកប្រតិបត្តិ
លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ

## តារាងមាតិកា


អារម្ភកថា

អក្សរកាត់ និងសន្ទានុក្រម

សារតា

ព្រឹត្តិការណ៍សំខាន់ៗនៃការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះ

គោលបំណង និងអ្នកប្រើប្រាស់សៀវភៅមគ្គុទេសក៍

ពាក្យបច្ចេកទេសផ្នែកយេនឌ័រ

**យេនឌ័រ និងភាពងាយរងគ្រោះក្នុងបរិបទរបស់គណៈកម្មការទន្លេមេគង្គ**

អភិក្រមណែនាំសម្រាប់ការបញ្ជ្រាបយេនឌ័ររបស់គណៈកម្មការទន្លេមេគង្គ

ការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការរៀបចំផែនការគាំពារ និងដំណើរការនានា

ការណែនាំ និងឧបករណ៍បញ្ជ្រាបយេនឌ័រ

ការបញ្ជ្រាបនៅក្នុងទិន្នន័យ ការតាមដាន និងព្យាករណ៍

ការបញ្ជ្រាបនៅក្នុងការចូលរួមពីភាគីពាក់ព័ន្ធ និងការប្រាស្រ័យទាក់ទង

ការពង្រឹងការបញ្ជ្រាបតាមស្ថាប័នរបស់គណៈកម្មការទន្លេមេគង្គ

ឯកសារយោង និងឯកសារណែនាំ

ការសិក្សាស្រាវជ្រាវពីយេនឌ័រ

ការបញ្ជ្រាបយេនឌ័រ៖ ឧបករណ៍ និងការអនុវត្តល្អៗ

ឯកសារណែនាំ

# អក្សរកាត់ និងសន្ទានុក្រម

| | |
|---|---|
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BDS | យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង |
| CSO | អង្គការសង្គមស៊ីវិល |
| DAGAP | ផែនការសកម្មភាពសម្រាប់ទទួល និងបង្កើតទិន្នន័យ |
| G&V | យេនឌ័រ និងភាពងាយរងគ្រោះ |
| GAP | ផែនការសកម្មភាពស្តីពីយេនឌ័រ |
| IUCN | សហភាពអន្តរជាតិសម្រាប់អភិរក្សធនធានធម្មជាតិ |
| LGBTIAQ+ | សហគមន៍ក្រុមឥន្ទ្ធ (ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ អ្នកប្តូរភេទ អត្តភេទ និងអ្នកមានចំណាប់អារម្មណ៍ទាបក្នុងការរួមភេទ) |
| MRC | គណៈកម្មការទន្លេមេគង្គ |
| MRC-SP | ផែនការយុទ្ធសាស្ត្ររបស់គណៈកម្មការទន្លេមេគង្គ |
| NMC | គណៈកម្មាធិការជាតិទន្លេមេគង្គ |
| OECD | អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ |
| UNISDR | ការិយាល័យអង្គការសហប្រជាជាតិសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ |
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| WHO | អង្គការសុខភាពពិភពលោក |

# សាវតា

នាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប្រទេសតាមដងទន្លេមេគង្គទាំងអស់ មានការរីកចម្រើនគួរឲ្យកត់សម្គាល់ទាក់ទងនឹងការអភិវឌ្ឍសង្គម និងសមភាពយេនឌ័រ ក្នុងនោះការទទួលបានសេវាកម្មសុខភាព និងការអប់រំត្រូវបានកែលម្អ, ស្ត្រីកាន់តែច្រើនបានបម្រើការក្នុងជំនាញវិជ្ជាជីវៈបច្ចេកទេស និងផ្លូវការ, គោលនយោបាយ និងគតិយុត្តថ្នាក់ជាតិជាច្រើនត្រូវបានរៀបចំឡើង ឆ្លើយតបទៅនឹងទម្រង់ផ្សេងៗនៃការរើសអើង។ ជាការពិតណាស់ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា អាស៊ាន) បានសង្កត់យ៉ាងធ្ងន់លើសារៈសំខាន់នៃសហគមន៍ដែលមានភាពធន់ និងការកាត់បន្ថយជាប្រព័ន្ធនៃភាពងាយរងគ្រោះ និងវិសមភាព។

ក៏ប៉ុន្តែ វានៅតែមានគម្លាត និងវិសមភាពខ្លាំង ដែលទាមទារឲ្យមានវិធានការភ្លាមៗ ផ្តោតលើបញ្ហាទាំងនេះ។ គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) ទទួលស្គាល់ថា ការអភិវឌ្ឍដោយចីរភាពក្នុងតំបន់អាងទន្លេមេគង្គ ពឹងផ្អែកលើសមភាពសង្គម និងភាពធន់នៃប្រជាជនរស់តាមដងទន្លេ ព្រមទាំងថាការអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាគោលនយោបាយ និងសកម្មភាពឲ្យចំគោលដៅ មានភាពចាំបាច់ណាស់ ដើម្បីដោះស្រាយបញ្ហាវិសមភាព។ កិច្ចការវិភាគពីមុនៗរបស់ MRC និងភាគីពាក់ព័ន្ធផ្សេងៗ បានបញ្ជាក់យ៉ាងច្បាស់ថា ស្ត្រី និងបុរស រួមវិភាគទានក្នុងការអភិវឌ្ឍធនធានទឹក ជាទូទៅ ជាមួយនឹងតួនាទីខុសគ្នានៃគុណតម្លៃដ៏សំខាន់ស្មើៗគ្នា។ ក៏ប៉ុន្តែ សម្លេងរបស់ស្ត្រីក្នុងការគ្រប់គ្រងធនធាន និងការសម្រេចចិត្ត នៅតែមានកម្រិតទាបនៅឡើយ។ ទិន្នន័យមិនពេញលេញ ពាក់ព័ន្ធនឹងយេនឌ័រ និងភាពងាយរងគ្រោះ ក្នុងតំបន់អាងទន្លេ បានបង្ហាញបន្ថែមទៀតថា ស្ត្រីទទួលបានប្រាក់កម្រៃទាបជាងបុរសក្នុងវិស័យពាក់ព័ន្ធទឹក, មានអំណាចតិចជាង និងទទួលបានប្រយោជន៍តិចជាងពីធនធាននានា ដែលពួកគេបានរួមចំណែក។

សមាសធាតុនៃភាពងាយរងគ្រោះ រួមមានស្ថានភាពសេដ្ឋកិច្ច ការអប់រំ ពិការភាព សមត្ថភាពប្រើប្រាស់ភាសា ការទទួលបាននូវមធ្យោបាយទំនាក់ទំនង អាយុ ដំណាក់កាលជីវិតខុសៗគ្នា ជាកត្តាខ្លះៗក្នុងចំណោមកត្តាផ្សេងទៀត ដែលផ្តល់ផលប៉ះពាល់ខ្លាំងលើភាពធន់នៃប្រជាជនរស់តាមដងទន្លេ និងត្រូវតែពិចារណានៅក្នុងការរៀបចំអភិវឌ្ឍន៍ ការអនុវត្ត និងការវាយតម្លៃលើរាល់សកម្មភាពដែលសំដៅលើការអភិវឌ្ឍអាងទន្លេដោយចីរភាពពិតប្រាកដ។ បើទោះជាយ៉ាងនេះក្តី វានៅតែពិបាកក្នុងការទទួលបានទិន្នន័យតាមផ្នែក ហើយជាញឹកញាប់ ទិន្នន័យដែលមានស្រាប់ មិនបានផ្សារភ្ជាប់ឲ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា ទៅនឹងដំណើរការសម្រេចចិត្ត និងការបែងចែកថវិកាទេ។ អាស្រ័យដូច្នេះ សហគមន៍តាមដងទន្លេត្រូវតែដោះស្រាយបញ្ហាគម្លាតទិន្នន័យបែបពហុវិមាត្រនេះជាបន្ទាន់។

ហេតុដូច្នេះ យុទ្ធសាស្ត្របច្ចុប្បន្នរបស់ MRC ចាប់ផ្តើមដោយវិធីសាស្ត្រផ្អែកយេនឌ័រ និងភាពងាយរងគ្រោះ (យ&រ) ដើម្បីឆ្លើយតបទៅនឹងវិសមភាពបែបអន្តរវិស័យ និងសមាសធាតុផ្សេងៗនៃភាពងាយរងគ្រោះ។

# ព្រឹត្តិការណ៍សំខាន់ៗនៃការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះ

MRC បានធ្វើការយ៉ាងសកម្ម ក្នុងការលើកកម្ពស់សមភាព និងសមធម៌យេនឌ័រក្នុងតំបន់អាងទន្លេមេគង្គ។ អស់រយៈពេលជាងពីរទសវត្សរ៍មកហើយ ដែលស្ថាប័នអន្តររដ្ឋាភិបាលមួយនេះ បានខិតខំលើកកម្ពស់ទាំងសមភាព និងសមធម៌ក្នុងចំណោមប្រជាជនរស់តាមដងទន្លេ ដោយទទួលស្គាល់ថា អភិបាលកិច្ចទឹកដោយចីរភាព មានទំនាក់ទំនងយ៉ាងខ្លាំងនឹងការអភិវឌ្ឍដោយត្រឹមត្រូវ និងការចូលរួមដោយស្មើភាពគ្នា ពីប្រជាជន ដែលពឹងអាស្រ័យលើធនធានទឹកទន្លេដោយផ្ទាល់ និងដោយប្រយោល។

បន្តិចម្តងៗ MRC បានធ្វើការបញ្ជ្រាបនៅក្នុងរចនាសម្ព័ន្ធស្ថាប័ន គោលការណ៍ណែនាំ យុទ្ធសាស្ត្រ និងគោលនយោបាយនានា សំដៅកែលម្អកិច្ចការរបស់ខ្លួន និងលើកកម្ពស់សមធម៌ក្នុងចំណោមប្រជាជនតាមដងទន្លេ។ ព្រឹត្តិការណ៍សំខាន់ខ្លះៗនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ រួមមាន៖

- ការកសាងមូលដ្ឋានគ្រឹះរឹងមាំមួយសម្រាប់ធ្វើការបញ្ជ្រាប ជាមួយនឹងយុទ្ធសាស្ត្រ និងគោលនយោបាយស្តីពីយេនឌ័រ នៅឆ្នាំ២០០០
- ការពង្រឹងសមត្ថភាពបច្ចេកទេស និងប្រព័ន្ធគណនេយ្យភាព សម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងកិច្ចការបច្ចេកទេសរបស់ MRC
- ការធ្វើស្ថាប័ននីយកម្មប្រព័ន្ធតាមដានយេនឌ័រ នៅតាមកម្មវិធី ការប្រឹក្សាយោបល់ និងកិច្ចប្រជុំនានារបស់ MRC
- ការធ្វើសមាហរណកម្មទស្សនាទានយេនឌ័រ និងភាពងាយរងគ្រោះ នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង និងផែនការយុទ្ធសាស្ត្ររបស់ MRC
- ការរៀបចំបង្កើតផែនការសកម្មភាពមួយស្តីពីយេនឌ័រដែលទទួលបានអនុម័ត
- ការបង្កើតសកម្មភាព កិច្ចការ និងថវិកាតាមយេនឌ័រ ឲ្យក្លាយជាផ្នែកមួយនៃផែនការការងាររយៈពេលវែង
- ការរៀបចំរបាយការណ៍ស្តីពីយេនឌ័រ និងភាពងាយរងគ្រោះ ពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានទឹកក្នុងតំបន់អាងទន្លេមេគង្គក្រោម នៅឆ្នាំ២០២១
- ការអភិវឌ្ឍវិធីសាស្ត្រប្រមូលទិន្នន័យតាមភេទ សង្គម-សេដ្ឋកិច្ច ដើម្បីរៀបចំទស្សនាទានយេនឌ័រឲ្យបានកាន់តែលម្អិត សម្រាប់របាយការណ៍ស្តីពីស្ថានភាពអាងទន្លេមេគង្គឆ្នាំ២០២៣ (ហៅកាត់ថា SOBR)។

ការរៀបចំបង្កើតសៀវភៅមគ្គុទេសក៍ស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាព និងមុខងារស្នូលរបស់ MRC៖ សៀវភៅណែនាំសម្រាប់អាងទន្លេមេគង្គក្រោមដែលមានភាពធន់ និងឆ្លើយតបនឹងយេនឌ័រ (ហៅកាត់ថា "សៀវភៅមគ្គុទេសក៍") គឺជាចំណាត់ការថ្មីបំផុតដែល MRC បានអនុវត្ត ដើម្បីដាក់បញ្ជ្រាបកិច្ចការបច្ចេកទេសរបស់ខ្លួន នៅក្នុងបរិបទកាន់តែទូលំទូលាយ ដោយផ្អែកលើវិធីសាស្ត្រឆ្លើយតបនឹងយេនឌ័រ និងភាពងាយរងគ្រោះ។

នៅក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងសម្រាប់ឆ្នាំ២០២១-២០៣០ សមាសធាតុសំខាន់ៗនៃយេនឌ័រ និងភាពងាយរងគ្រោះ ទទួលបានការយកចិត្តទុកដាក់ជាពិសេស។ ជាលទ្ធផល បច្ចុប្បន្ននេះ អ្នកអាចរកឃើញធាតុផ្សេងៗនៃយេនឌ័រ និងភាពងាយរងគ្រោះ នៅគ្រប់ជំពូកទាំងអស់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ហើយផែនការយុទ្ធសាស្ត្ររបស់ MRC ក៏មានគោលបំណងពង្រឹងព័ត៌មានតាមផ្នែក និងធ្វើសមាហរណកម្មសមាសភាគសមភាពផ្សេងៗ រួមចំណែកដល់ការអភិវឌ្ឍប្រកបដោយភាពយុត្តិធម៌ និងសមធម៌សង្គមសម្រាប់សហគមន៍តាមដងទន្លេផងដែរ។ គោលដៅនេះ ស្របនឹងចក្ខុវិស័យអាស៊ានសម្រាប់សហគមន៍ដែលមានភាពធន់ និងស្និតស្នាញ ហើយវាឆ្លុះបញ្ចាំងពីសារៈសំខាន់ដែលយេនឌ័រ និងភាពងាយរងគ្រោះទទួលបាននៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (ហៅកាត់ថា SGDs)។

កង្វះខាតរួមនៃទិន្នន័យតាមផ្នែក ត្រូវបានគេរំលេចជាបញ្ហាដ៏សំខាន់មួយនៃសកម្មភាព ដោយហេតុថាដើម្បីរៀបចំបង្កើតយន្តការដាក់លាក់នៅកម្រិត MRC និងតាមបណ្តាលប្រទេសជាសមាជិក គេត្រូវតែបង្កើនបរិមាណព័ត៌មានស្តីពីស្ថានភាពបច្ចុប្បន្ន បញ្ហាប្រឈម និងចំណុចខ្លាំងនានានៃក្រុមប្រជាជនខុសៗគ្នា។ កិច្ចការនេះ នឹងជួយធ្វើឲ្យការដាក់បញ្ចូលធាតុផ្សេងៗនៃសមភាពឲ្យកាន់តែមានអត្ថន័យ និងរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយភាពយុត្តិធម៌ និងសមធម៌សង្គមសម្រាប់សហគមន៍តាមដងទន្លេ។

បញ្ហាសង្គមសំខាន់ៗ ដែលគេបានត្រិះរិះម្តងហើយម្តងទៀត នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់អាងទន្លេទាំងមូល រួមមានសន្តិសុខស្បៀងអាហារ ការគ្រប់គ្រងគ្រោះអាសន្នឆ្លើយតបនឹងយេនឌ័រ និងភាពងាយរងគ្រោះ និងវិសមភាពនៃការប្រើប្រាស់ និងកាលានុវត្តន៍នានា ទាក់ទងនឹងធនធានទឹក ដូចជាការទទួលបានទឹកសុវត្ថិភាពសម្រាប់ប្រើប្រាស់ និងវិសមភាពក្នុងកិច្ចការដែលមាន និងគ្មានប្រាក់កម្រៃ។ យោងលើមូលដ្ឋានព័ត៌មាននេះ ផែនការយុទ្ធសាស្ត្រ MRC រួមបញ្ចូលទាំងយន្តការផ្តោតលើយេនឌ័រ និងភាពងាយរងគ្រោះ (ឧ. ការវិភាគមួយសម្រាប់ធាតុយេនឌ័រ និងភាពងាយរងគ្រោះនៃសន្តិសុខទឹក ស្បៀងអាហារ និងថាមពលសម្រាប់អាងទន្លេ) និងយន្តការនានា ដែលផ្តោតបន្ថែមលើការបញ្ជ្រាបយេនឌ័រ (ឧ. សមាហរណកម្មចក្ខុវិស័យផ្នែកភាពងាយរងគ្រោះ ក្នុងកិច្ចខិតខំប្រឹងប្រែងរៀបចំផែនការរួម និងផែនការពហុវិមាត្រ)។ ផែនការសកម្មភាពមួយស្តីពីយេនឌ័រ ត្រូវបានរៀបចំអភិវឌ្ឍឡើងជាឯកសារអមនឹងផែនការយុទ្ធសាស្ត្រ MRC។ គេអាចឃើញផែនការនេះ ជាឧបសម្ព័ន្ធមួយនៃផែនការយុទ្ធសាស្ត្របច្ចុប្បន្នរបស់ MRC រីឯការតាមដាននៃសកម្មភាពនានា គឺជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំ។

# គោលបំណង និងអ្នកប្រើប្រាស់សៀវភៅមគ្គុទេសក៍

សៀវភៅមគ្គុទេសក៍នេះ មានគោលបំណងជួយឲ្យ MRC ធ្វើសមាហរណកម្មទស្សនាទានយេនឌ័រ នៅក្នុងគ្រប់ផ្នែកទាំងអស់នៃកិច្ចការរបស់ខ្លួនឲ្យមានប្រសិទ្ធិភាព ដោយរាប់ចាប់ពីការអភិវឌ្ឍ ការធ្វើបច្ចុប្បន្នភាព និងការប្រើប្រាស់ឧបករណ៍យុទ្ធសាស្ត្រ នីតិវិធី គោលការណ៍បទដ្ឋាន ការសិក្សាស្រាវជ្រាវ និងការពង្រឹងស្ថាប័ន រហូតដល់ការរៀបចំបង្កើត និងកិច្ចគាំពារលើគ្រប់សកម្មភាពរួមទាំងអស់។ វាមានគោលដៅពង្រឹងសមត្ថភាព MRC ជំរុញឲ្យបង្កើតបរិយាកាសមានអំណោយផល និងប្រកបដោយបរិយាបន្នសម្រាប់គ្រប់ភាគីពាក់ព័ន្ធ និងយេនឌ័រទាំងអស់ ដើម្បីឲ្យប្រជាជនរស់តាមដងទន្លេមេគង្គ អាចចូលរួមចំណែក និងទទួលបានប្រយោជន៍ពីការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកដោយចីរភាព។ ហើយទីបំផុត វានឹងក្លាយជាវិភាគទានមួយ និងជួយនាំយើងឆ្ពោះទៅរកសមិទ្ធផលអភិវឌ្ឍន៍ប្រកបដោយភាពត្រឹមត្រូវ និងចីរភាព។

អ្នកប្រើប្រាស់ចម្បងនៃសៀវភៅមគ្គុទេសក៍នេះ គឺជាបុគ្គលិកនៃលេខាធិការដ្ឋាន MRC និងមន្ត្រីមកពីបណ្ដាលប្រទេសជាសមាជិកទាំងបួន ជាពិសេសបុគ្គលិកបច្ចេកទេស ដែលស្វែងរកការណែនាំសម្រាប់ការបញ្ជ្រាបឲ្យបានទៀងទាត់នូវសមាសធាតុយេនឌ័រ និងភាពងាយរងគ្រោះនៅក្នុងកិច្ចការរបស់ខ្លួន។ ថ្នាក់ដឹកនាំ MRC អាចប្រើប្រាស់សៀវភៅនេះ ធ្វើការសម្រេចចិត្តបែបយុទ្ធសាស្ត្រ សម្រាប់តម្រូវការបញ្ជ្រាបយេនឌ័របន្ថែមទៀត និងដើម្បីធានាឲ្យមានវិធីសាស្ត្ររួមមួយ សម្រាប់សកម្មភាពឆ្លើយតបនឹង និងការប្រើប្រាស់ភាសាដោយពិចារណាពីយេនឌ័រ និងភាពងាយរងគ្រោះ។ បន្ថែមពីនេះ មន្ត្រីជំនាញផ្នែកអភិបាលកិច្ចទឹក ក្រៅពី MRC ក៏អាចទទួលបានប្រយោជន៍ពីឯកសារនេះ ដើម្បីលើកកម្ពស់ការខិតខំក្នុងការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះ នៅតាមតំបន់កិច្ចការបច្ចេកទេសផ្សេងៗគ្នានៃអភិបាលកិច្ចទឹក ដោយប្រើប្រាស់សៀវភៅនេះទៅតាមស្ថានភាព និងបរិបទរបស់ខ្លួន។

សៀវភៅមគ្គុទេសក៍នេះ នឹងផ្តល់នូវ៖

- ទិដ្ឋភាពរួមមួយនៃពាក្យបច្ចេកទេសផ្នែកយេនឌ័រ ពាក់ព័ន្ធនឹងកិច្ចការរបស់ MRC
- អភិក្រមណែនាំនានា សម្រាប់ការបញ្ជ្រាបយេនឌ័រ
- ការណែនាំក្នុងការបញ្ជ្រាបយេនឌ័រ នៅក្នុងនីតិវិធី និងដំណើរការរៀបចំផែនការនានា ដោយផ្តោតលើបច្ចុប្បន្នភាព និងការអភិវឌ្ឍគោលការណ៍ណែនាំយុទ្ធសាស្ត្រ និងបច្ចេកទេសសម្រាប់អាងទាំងមូល
- ការណែនាំពីការបញ្ជ្រាបយេនឌ័រនៅក្នុងទិន្នន័យ ការតាមដាន និងព្យាករណ៍
- ការណែនាំពីការបញ្ជ្រាបយេនឌ័រនៅក្នុងការចូលរួមពីភាគីពាក់ព័ន្ធ និងការប្រាស្រ័យទាក់ទង
- ការណែនាំដើម្បីពង្រឹងការបញ្ជ្រាបយេនឌ័រតាមស្ថាប័នរបស់ MRC
- ឯកសារយោងដែលមានប្រយោជន៍បន្ថែមទៀត និងតំណស្រាវជ្រាវពីមុនៗ

សៀវភៅមគ្គុទេសក៍នេះ ជាឯកសារជំនួយដល់ការដាក់បញ្ចូលដ៏មានប្រសិទ្ធភាពនូវសមាសធាតុយេនឌ័រ និងភាពងាយរងគ្រោះទៅក្នុងសកម្មភាពស្នូលរបស់ MRC។ ហេតុដូច្នេះ ការប្រើប្រាស់សៀវភៅនេះ នឹងមិនត្រូវពិនិត្យតាមដានដាច់ដោយឡែកឡើយ ក៏ប៉ុន្តែបុគ្គលិកលេខាធិការដ្ឋាន MRC និងប្រទេសជាសមាជិកនឹងទទួលបានការអញ្ជើញឲ្យត្រួតពិនិត្យសៀវភៅនេះឡើងវិញ ជាឯកសារមួយដែលទទួលបានការកែសម្រួល និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ក្នុងអំឡុងពេលប្រើប្រាស់វា។

# ពាក្យបច្ចេកទេសសំខាន់ៗពីយេនឌ័រ

## យេនឌ័រ និងភាពងាយរងគ្រោះ ក្នុងបរិបទរបស់គណៈកម្មការទន្លេមេគង្គ

នាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ប្រទេសតាមដងទន្លេមេគង្គទាំងអស់ មានការរីកចម្រើនគួរឲ្យកត់សម្គាល់ទាក់ទងនឹងការអភិវឌ្ឍសង្គម និងសមភាពយេនឌ័រ។ ការទទួលបានសេវាកម្មសុខភាព និងការអប់រំមានភាពប្រសើរឡើង, ស្ត្រីកាន់តែច្រើនបានបម្រើការក្នុងជំនាញវិជ្ជាជីវៈបច្ចេកទេស និងផ្លូវការ, គោលនយោបាយ និងគតិយុត្តថ្នាក់ជាតិជាច្រើនត្រូវបានដាក់ឲ្យប្រើប្រាស់ ប្រឆាំងទៅនឹងទម្រង់ផ្សេងៗនៃការរើសអើង ហើយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថា អាស៊ាន) ក៏បានសង្កត់ធ្ងន់លើសារៈសំខាន់នៃសហគមន៍ដែលមានភាពធន់ និងការកាត់បន្ថយជាប្រព័ន្ធនៃភាពងាយរងគ្រោះ និងវិសមភាពផងដែរ។

ក៏ប៉ុន្តែ វានៅតែមានគម្លាត និងវិសមភាពខ្លាំង ដែលទាមទារឲ្យមានវិធានការភ្លាមៗ ផ្តោតលើបញ្ហាទាំងនេះ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ទទួលស្គាល់ថា ការអភិវឌ្ឍដោយចីរភាពក្នុងតំបន់អាងទន្លេមេគង្គ ពឹងអាស្រ័យលើសមភាពសង្គម និងភាពធន់នៃប្រជាជនរស់តាមដងទន្លេ។ ការអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាគោលនយោបាយ និងសកម្មភាពឲ្យចំគោលដៅ មានភាពចាំបាច់ណាស់ ដើម្បីដោះស្រាយបញ្ហាវិសមភាព។

ហេតុដូច្នេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ចាប់ផ្តើមពីវិធីសាស្ត្រផ្នែកយេនឌ័រ និងភាពងាយរងគ្រោះ (យ&រ) ដើម្បីឆ្លើយតបទៅនឹងវិសមភាពបែបអន្តរវិស័យ និងសមាសធាតុផ្សេងៗនៃភាពងាយរងគ្រោះ។

បទពិសោធន៍មេរៀន ដែលទទួលបានពីកិច្ចការវិភាគពីមុនរបស់ MRC និងភាគីពាក់ព័ន្ធផ្សេងៗ បញ្ជាក់ថា ស្ត្រី និងបុរស រួមចំណែកលើការអភិវឌ្ឍធនធានទឹក ដោយជាទូទៅ មានតួនាទីខុសៗគ្នានៃគុណតម្លៃដ៏សំខាន់ដោយស្មើភាពគ្នា ក៏ប៉ុន្តែសំលេងរបស់ស្ត្រីនៅក្នុងការគ្រប់គ្រងធនធាន និងការសម្រេចចិត្ត នៅតែមានកម្រិតទាបនៅឡើយ។

សមាសធាតុនៃភាពងាយរងគ្រោះ រួមមានស្ថានភាពសេដ្ឋកិច្ច ការអប់រំ ពិការភាព សមត្ថភាពប្រើប្រាស់ភាសា ការទទួលបាននូវមធ្យោបាយទំនាក់ទំនង អាយុ ដំណាក់កាលជីវិតខុសៗគ្នា ជាកត្តាជាច្រើនក្នុងចំណោមកត្តាផ្សេងទៀត ដែលមានផលប៉ះពាល់ខ្លាំងលើភាពធន់នៃប្រជាជនរស់តាមអាងទន្លេ និងត្រូវតែដាក់ពិចារណានៅក្នុងការរៀបចំគម្រោង ការអនុវត្ត និងការវាយតម្លៃលើរាល់សកម្មភាព ដែលសំដៅលើការអភិវឌ្ឍអាងទន្លេដោយចីរភាពពិតប្រាកដ។ បើទោះជាយ៉ាងនេះក្តី វានៅតែពិបាកក្នុងការទទួលបានទិន្នន័យតាមផ្នែក ហើយជាញឹកញាប់ ទិន្នន័យដែលមានស្រាប់ មិនបានផ្សារភ្ជាប់ឲ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា ទៅនឹងដំណើរការសម្រេចចិត្ត និងការបែងចែកថវិកាទេ។ អាស្រ័យដូច្នេះ សហគមន៍តាមដងទន្លេត្រូវតែដោះស្រាយបញ្ហាគម្លាតទិន្នន័យពហុវិមាត្រនេះជាបន្ទាន់។

MRC ប្រើប្រាស់និយមន័យដូចបានបង្ហាញនៅខាងក្រោមនេះ នៅពេលធ្វើការលើកកម្ពស់វិធីសាស្ត្រផ្នែក

យេនឌ័រ និងភាពងាយរងគ្រោះ។

| | |
|---|---|
| **យេនឌ័រ** | យោងតាមអង្គការសុខភាពពិភពលោក (ហៅកាត់ថា WHO) យេនឌ័រ សំដៅលើតួនាទី ការប្រព្រឹត្ត សកម្មភាព ចរិតលក្ខណៈ និងកាលានុវត្តន៍នានា ដែលសង្គមមួយគិតថាសាកសមសម្រាប់កុមារា និងកុមារី ស្ត្រី និងបុរស។ យេនឌ័រ មានអន្តរទំនាក់ទំនងជាមួយនឹង ប៉ុន្តែវាខុសពីកត្តាទ្វេភាគនៃភេទបែបជីវសាស្ត្រ។[1] ដូច្នេះ ការយល់ដឹងបែបនេះពីយេនឌ័រ ត្រូវបានបង្កើតឡើងដោយកត្តាសង្គម។ យេនឌ័រ ត្រូវបានគេយល់ដឹងកាន់តែច្រើនឡើង ដោយមិនសំដៅលើទ្វេភាគទេ ប៉ុន្តែលើវិសាលគមមួយទៅវិញ។ ចំនួនប្រជាជនកាន់តែច្រើនឡើង កំពុងធ្វើការកំណត់អត្តសញ្ញាណ លើតំណាងសម្ព័ន្ធមួយ រវាងស្ត្រី និងបុរស ឬអភេទ (មិនស្រី ហើយក៏មិនមែនប្រុស)។ ត្រង់នេះ គេហៅថាអត្តសញ្ញាណយេនឌ័រ។[2] |
| **ភេទ** | ភេទ សំដៅលើកត្តាជីវសាស្ត្ររបស់បុគ្គលម្នាក់ កំណត់ដោយសរីរវិទ្យារបស់សាមីបុគ្គល។ ជាទូទៅ វាសំដៅលើភេទប្រុស ឬស្រី និងត្រូវបានកំណត់ពីកំណើត ទោះបីជាភាពចម្រុះបែបជីវសាស្ត្រពិតប្រាកដ មិនមែនទ្វេភាគ[3]ក៏ដោយ។ |
| **សមភាពយេនឌ័រ** | វាសំដៅលើកង្វះនៃការរើសអើង ដោយផ្អែកលើភេទរបស់បុគ្គលម្នាក់ ពាក់ព័ន្ធនឹងការទទួលបានឱកាស ការបែងចែកធនធាន និងប្រយោជន៍ផ្សេងៗ ឬការទទួលបានសេវានានាសម្រាប់ប្រើប្រាស់។[4] សមភាពយេនឌ័រ កើតមាន នៅពេលដែលប្រជាជនគ្រប់យេនឌ័រទាំងអស់មានសិទ្ធិ ករណីកិច្ច និងឱកាសស្មើៗគ្នា។ បុគ្គលគ្រប់រូប រងគ្រោះពីវិសមភាពយេនឌ័រ ក្នុងនោះមានស្ត្រី បុរស អ្នកប្តូរភេទ និងមានភេទចម្រុះ កុមារ និងក្រុមគ្រួសារ។ វាប៉ះពាល់ដល់ប្រជាជនគ្រប់វ័យ និងសាវតាទាំងអស់។ សមភាពយេនឌ័រ គឺជាសិទ្ធិមនុស្ស ដែលប្រជាជនគ្រប់រូបទទួលបានប្រយោជន៍ពីវា។[5] |

[1] សូមមើលអង្គការសុខភាពពិភពលោក (២០២០)។

[2] សូមមើល ជាឧទាហរណ៍ និយមន័យពីការិយាល័យសម្រាប់ស្ថិតិជាតិរបស់រដ្ឋាភិបាលអង់គ្លេស (២០១៩)។

[3] ដើម្បីសិក្សាបន្ថែមពីវិសាលគមយេនឌ័រ សូមមើលវិសាលគមយេនឌ័រ (២០១៩)។

[4] សូមមើលអង្គការសុខភាពពិភពលោក សហភាពអឺរ៉ុប (២០២០)។

[5] នេះអាស្រ័យលើនិយមន័យ និងឧទាហរណ៍ពីរបៀបដែលវិសមភាពយេនឌ័រ មានឥទ្ធិពលលើបុគ្គលគ្រប់រូប និងរបៀបដែលសមភាពផ្តល់ប្រយោជន៍ឲ្យគ្រប់ពលរដ្ឋទាំងអស់។ សូមមើលរដ្ឋនៃរដ្ឋាភិបាលវិកតូរីយ៉ា (រដវ, ២០១៩)។

| | |
|---|---|
| **សមធម៌យេនឌ័រ** | វាសំដៅលើភាពត្រឹមត្រូវ និងយុត្តិធម៌ក្នុងការបែងចែកប្រយោជន៍ និងការទទួលខុសត្រូវរវាងយេនឌ័រខុសៗគ្នា។ គោលគំនិតនេះ ទទួលស្គាល់ថា ប្រជាជនគ្រប់យេនឌ័រទាំងអស់ មានតម្រូវការ និងអំណាចខុសៗគ្នា ហើយថាភាពខុសគ្នាទាំងនេះគប្បីត្រូវបានកំណត់ និងដោះស្រាយនៅក្នុងឥរិយាបទមួយ ដែលជួយធ្វើឲ្យភាពខុសគ្នាទាំងនេះមានតុល្យភាព។[6] ដើម្បីធានាឲ្យមានភាពយុត្តិធម៌ ជាញឹកញាប់ គេត្រូវតែមានយុទ្ធសាស្ត្រ និងយន្តការសម្រាប់ធ្វើការតបស្នងដល់ស្ត្រីដែលរងគ្រោះពីបន្ទុកសង្គម និងប្រវត្តិសាស្ត្រ ដែលរារាំងស្ត្រី និងបុរសពីប្រតិបត្តិការផ្សេងៗនៅតាមវិស័យការងារ។ សមធម៌ នាំឲ្យមានសមភាព។[7] |
| **ការបញ្រ្ជាបយេនឌ័រ** | ការបញ្រ្ជាបយេនឌ័រ គឺជាដំណើរការទាំងផ្នែកបច្ចេកទេស និងនយោបាយ ដែលតម្រូវឲ្យមានការផ្លាស់ប្តូរនានានៅក្នុងវប្បធម៌ស្ថាប័ន និងការត្រិះរិះពិចារណា ក៏ដូចជានៅក្នុងគោលដៅ រចនាសម្ព័ន្ធ និងការបែងចែកធនធាននានា។ វាក៏រួមបញ្ចូលនូវការវាយតម្លៃពីផលវិបាកនានា សម្រាប់ស្ត្រី និងបុរសសម្រាប់សកម្មភាពណាមួយដែលបានគ្រោងទុក រួមទាំងនីតិប្បញ្ញត្តិ គោលនយោបាយ ឬកម្មវិធីផ្សេងៗ ក្នុងតំបន់គម្រោងណាមួយ និងនៅគ្រប់កម្រិតទាំងអស់។ វាក៏ជាយុទ្ធសាស្ត្រមួយ ធ្វើឲ្យក្តីបារម្ភ និងបទពិសោធន៍របស់ស្ត្រី និងបុរសក្លាយជាចំណុចស្នូលមួយ នៅក្នុងការរៀបចំផែនការ ការអនុវត្ត ការតាមដាន និងការវាយតម្លៃគោលនយោបាយ និងកម្មវិធីនានា នៅគ្រប់បរិបទនយោបាយ សេដ្ឋកិច្ច និងសង្គមទាំងអស់ ដែលវិសមភាពរវាងស្ត្រី និងបុរសត្រូវបានបញ្ឈប់។ គោលដៅចុងក្រោយ គឺសម្រេចឲ្យបាននូវសមភាពយេនឌ័រ។<br><br>កិច្ចការបញ្រ្ជាបនេះ ទាមទារឲ្យមានការផ្លាស់ប្តូរនៅកម្រិតខុសៗគ្នា ក្នុងស្ថាប័ននានាក្នុងការកំណត់របៀបវារៈ ការបង្កើតគោលនយោបាយ ការរៀបចំផែនការ ការអនុវត្ត និងការវាយតម្លៃ។ ឧបករណ៍បញ្រ្ជាបនានា រួមបញ្ចូលនូវការជ្រើសរើសបុគ្គលិកថ្មី និងការអនុវត្តរៀបចំថវិកា កម្មវិធីបណ្តុះបណ្តាល នីតិវិធីគោលនយោបាយ និងគោលការណ៍ណែនាំនានា។[8]<br><br>*សម្គាល់៖* និយមន័យទូទៅនៃការបញ្រ្ជាបយេនឌ័រ គឺមានលក្ខណៈទ្វេភាគ (ស្ត្រី និងបុរស)។ ប៉ុន្តែ នៅក្នុងយន្តការវាយតម្លៃ និងរៀបចំគម្រោង ការយល់ដឹងពីយេនឌ័រ គប្បីមានលក្ខណៈទូលំទូលាយជាង បើយោងតាមនិយមន័យពីមុន ជាពិសេសដើម្បីធានាឲ្យមានការរើសអើងតាមអន្តរវិស័យ និងបន្ថែមទៀត (សូមមើលខាងក្រោម) តួយ៉ាងដូចជាក្រុមស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស ក្រុមអ្នកស្រលាញ់ទាំងពីរភេទ អ្នកប្តូរភេទ អន្តរភេទ និងអ្នកមានចំណាប់អារម្មណ៍ទាបក្នុងការរួមភេទ (សហគមន៍ក្រុមឥន្ទ្រ)។ |

[6] សូមមើលអង្គការសុខភាពពិភពលោក សហភាពអឺរ៉ុប (២០២០)។

[7] សូមមើលអង្គការហ្វោវ (២០០៥)។

[8] សូមមើលអង្គការសុខភាពពិភពលោក សហភាពអឺរ៉ុប (២០២០)។

| | |
|---|---|
| **ការរើសអើងតាមអន្តរវិស័យ** | ការរើសអើងតាមអន្តរវិស័យ គឺអាស្រ័យលើសាវតាបុគ្គល ឬលក្ខណៈសម្បត្តិ/អត្តសញ្ញាណ ដែលបុគ្គលបានប្រព្រឹត្ត និងប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដទៃទន្ទឹមពេលគ្នា នៅក្នុងឥរិយាបទមួយដែលមិនអាចបែងចែកឲ្យដាច់ពីគ្នាបាន។[9] បុគ្គលដែលទទួលការរើសអើង ព្រោះកត្តាជាតិសាសន៍ ក៏អាចនឹងរងគ្រោះពីការរើសអើងដោយសារកត្តាយេនឌ័រ ទំនោរភេទ សាសនា ឬជំនឿ អាយុ ឬពិការភាពផងដែរ។ ការរើសអើងបែបនេះ អាចបង្កើតឲ្យមានគុណវិបត្តិរួម។[10] នៅតាមបណ្តាលប្រទេសតាមអាងទន្លេមេគង្គ វាអាចទៅរួចក្នុងការសង្កេតឃើញពីរនាំងដ៏តឹងរឹងសម្រាប់ស្ត្រីជនជាតិភាគតិច ស្ត្រីវ័យចំណាស់ ស្ត្រីពិការ និងបុរសមានវ័យខុសៗគ្នា ក្រុមសហគមន៍ពណ៌ឥន្ទនូនៃក្រុមវ័យផ្សេងៗគ្នា ឬសមាជិកជនជាតិភាគតិចវ័យជំទង់។ |
| **ការឆ្លើយតបដោយពិចារណាពីយេនឌ័រ និងការឆ្លើយតបនឹងយេនឌ័រ** | ដើម្បីធ្វើការកំណត់អត្តសញ្ញាណ និងស្វែងយល់ពីគម្លាតយេនឌ័រ និងការរើសអើងនានា ដើម្បីចាត់វិធានលើបញ្ហាទាំងនេះ វាចាំបាច់ត្រូវរៀបចំអភិវឌ្ឍ និងអនុវត្តសកម្មភាពនានា ដើម្បីជំនះលើរាល់បញ្ហាប្រឈម និងឧបសគ្គទាំងអស់ ធ្វើឲ្យប្រសើរឡើងនូវសមភាពយេនឌ័រ។ បើប្រៀបធៀបទៅនឹងការឆ្លើយតបដោយពិចារណាពីយេនឌ័រ (ការឈ្វេងយល់ និងថ្លឹងថ្លែងពីកត្តាវប្បធម៌-សង្គម ដែលនៅពីក្រោយការរើសអើងតាមភេទ) ការឆ្លើយតបនឹងយេនឌ័រ មានអត្ថន័យលើសពី ‘ការមិនបង្កហានិភ័យ’ ដែលបច្ចុប្បន្ននេះ វាមានន័យថា ‘ធ្វើឲ្យបានកាន់តែប្រសើរ’។ ដូច្នេះ វិធីសាស្ត្រឆ្លើយតបនឹងយេនឌ័រ មានលក្ខណៈកាន់តែបុរេសកម្ម អាចបែងចែកធនធានសម្រាប់ការវិភាគផ្នែកយេនឌ័រ និងប្រើប្រាស់វិធីសាស្ត្របែបយុទ្ធសាស្ត្រ អនុវត្តយន្តការនានាក្នុងការដោះស្រាយរាល់ឧបសគ្គដែលបានកំណត់ ដូចជាការបង្កើនមុខរបរសម្រាប់ស្ត្រី និងកុមារី តាមរយៈការពង្រឹងការទទួលបាន និងការគ្រប់គ្រងធនធាន និងសេវាកម្មផលប្រយោជន៍ ការចូលរួម និងការសម្រេចចិត្ត។ យុទ្ធសាស្ត្រនេះ ជួយធានាថា គោលនយោបាយ កម្មវិធី ឬគម្រោងនានារបស់ MRC មិនបានធ្វើឲ្យវិសមភាព មានស្ថានភាពកាន់តែអាក្រក់នោះទេ ប៉ុន្តែវាបានវិវឌ្ឍទៅមុខដោយមានអត្ថន័យ ក្នុងការកាត់បន្ថយគម្លាតនានា និងផ្តល់អំណាចដល់ស្ត្រី កុមារី និងសមាជិកផ្សេងៗនៃក្រុមប្រជាជនដែលរងគ្រោះពីប្រពៃណី។[11] |

9 សូមមើលវិទ្យាស្ថានអឺរ៉ុបសម្រាប់សមភាពយេនឌ័រ (វអសយ, ២០២០ក) ស្តីពីការរើសអើងតាមអន្តរវិស័យ សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត។

10 សហភាពអឺរ៉ុប (សអ, ២០១៦)។

11 យោងលើនិយមន័យរបស់សហភាពអន្តរជាតិសម្រាប់អភិរក្សធនធានធម្មជាតិ។ សូមមើលសអអធ (២០១៨) សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត។

| | |
|---|---|
| **ការរៀបចំថវិកាយេនឌ័រ** | ការរៀបចំថវិកាយេនឌ័រ គឺជាកម្មវិធីមួយនៃការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការរៀបចំថវិកា។ វាពាក់ព័ន្ធនឹងការរៀបចំការវាយតម្លៃផ្នែកយេនឌ័រនៃថវិកានានា ដោយដាក់បញ្ចូលទស្សនាទានយេនឌ័រទៅគ្រប់កម្រិតទាំងអស់នៃដំណើរការរៀបចំថវិកា និងរៀបចំរចនាសម្ព័ន្ធចំណូល និងចំណាយឡើងវិញ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ។ សរុបមក ការរៀបចំថវិកាយេនឌ័រ គឺជាយុទ្ធសាស្ត្រ និងដំណើរការរយៈពេលវែងមួយ សំដៅសម្រេចឲ្យបាននូវគោលដៅសមភាពយេនឌ័រ។<br><br>ការរៀបចំថវិកាយេនឌ័រ មានគោលបំណងដាក់បញ្ចូលនូវស្ថានភាពរស់នៅជាក់ស្តែងរបស់ស្ត្រី និងបុរសទៅក្នុងថវិកា និងរំលេចពីវិសមភាពដែលមានកើតជាក់ស្តែង ក្នុងការរៀបចំថវិកា។ នៅក្នុងការអនុវត្ត ការរៀបចំថវិកាយេនឌ័រ លាតបង្ហាញពីផលប៉ះពាល់ផ្សេងគ្នានៃការសម្រេចចិត្តលើប្រាក់ចំណូល និងការចំណាយលើស្ត្រី និងបុរសដែលមានលក្ខណៈខុសៗគ្នា តាមដំណាក់កាលនៃជីវិត និងស្ថានភាពសេដ្ឋកិច្ច និងសង្គម។ បន្ថែមពីនេះ វាទាមទារឲ្យមានការត្រួតពិនិត្យលើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុសាធារណៈ ជានាថាថវិកាទាំងនេះ នឹងរួមចំណែកធ្វើឲ្យប្រសើរឡើងនូវសមភាពយេនឌ័រ ជាជាងការពង្រឹងនូវវិសមភាពដែលមានស្រាប់។ |
| **ស្ថិតិយេនឌ័រ (ទិន្នន័យតាមភេទ/តាមយេនឌ័រ)** | ស្ថិតិយេនឌ័រ ឆ្លុះបញ្ចាំងយ៉ាងពេញលេញនូវភាពខុសគ្នា និងគម្លាតផ្សេងៗពីស្ថានភាពរស់នៅរបស់ស្ត្រី និងបុរសនៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត។ ស្ថិតិទាំងនេះ ត្រូវបានកំណត់ដោយលក្ខណៈសម្បត្តិដូចខាងក្រោមនេះ៖<br><br>• ទិន្នន័យ ត្រូវបានប្រមូល និងបង្ហាញតាមភេទ ទៅតាមប្រភេទក្រុមសំខាន់ៗ និងក្រុមជារួម (ទិន្នន័យតាមភេទ)<br>• ទិន្នន័យ ឆ្លុះបញ្ចាំងពីបញ្ហាយេនឌ័រនានា<br>• ទិន្នន័យ ផ្អែកលើគោលគំនិត និងនិយមន័យ ដែលឆ្លុះបញ្ចាំងពេញលេញពីភាពចម្រុះនៃស្ត្រី និងបុរស និងចាប់យកគ្រប់ទិដ្ឋភាពនៃជីវិតរបស់ពួកគេ<br>• វិធីសាស្ត្រប្រមូលទិន្នន័យ ដោយពិចារណាពីផ្នត់គំនិត កត្តាសង្គម និងវប្បធម៌ ដែលអាចកាត់បន្ថយភាពលម្អៀងផ្នែកយេនឌ័រនៅក្នុងទិន្នន័យ។[12]<br><br>*សម្គាល់៖* វាមិនបានធ្វើឲ្យស្ថិតិផ្សេងទៀតក្លាយជាវិធីសាស្ត្រទ្វេភាគ (ស្ត្រី/បុរស) ដោយស្វ័យប្រវត្តិទេ ប៉ុន្តែវាលើកជាសំណើឲ្យដាក់យេនឌ័រ និងភាពងាយរងគ្រោះ ទៅក្នុងបរិបទដោយថ្លឹងថ្លែងថា **តើយើងត្រូវការព័ត៌មានអ្វីខ្លះ ដើម្បីស្វែងយល់ពីបញ្ហាប្រឈម និងកាលានុវត្តន៍នានាឲ្យបានគ្រប់ជ្រុងជ្រោយ?** |

[12] UNSTATS (២០១៥) ផ្តល់នូវការបកស្រាយដ៏ល្អមួយពីអត្ថន័យនៃស្ថិតិយេនឌ័រ និងមូលហេតុដែលពាក្យ 'ទិន្នន័យតាមយេនឌ័រ' ជាពាក្យដែលមានន័យងាយនឹងធ្វើឲ្យមានការភាន់ច្រលំ។

| | |
|---|---|
| **សូចនាករយេនឌ័រ** | ពាក្យ 'ទិន្នន័យតាមយេនឌ័រ' ធ្វើឲ្យមានការយល់ច្រលំកើតមាន ព្រោះថា ពាក្យនេះភាគច្រើន ពណ៌នាពីវិធីសាស្ត្រមួយ ក្នុងការប្រមូលទិន្នន័យ 'តាមភេទ' ដ៏សាមញ្ញ។ ការប្រមូលទិន្នន័យ ដោយផ្អែកលើភេទបែបជីវសាស្ត្រ ('តាមភេទ') គ្រាន់តែជាផ្នែកមួយនៃស្ថិតិយេនឌ័រប៉ុណ្ណោះ។ ដើម្បីស្វែងយល់ពីតួនាទីខុសៗគ្នា ឱកាស និងឧបសគ្គរបស់ប្រជាជនគ្រប់យេនឌ័រទាំងអស់ វាចាំបាច់ណាស់ក្នុងការអនុវត្តឲ្យបានច្រើនជាងនេះ និងព្យាយាមយល់ដឹងពីប្រព័ន្ធអំណាច និងរនាំងផ្នែករចនាសម្ព័ន្ធពាក់ព័ន្ធនឹងអភិបាលកិច្ចទឹកបែបបរិយាបន្ន និងការទទួលបានធនធាននានាសម្រាប់ប្រើប្រាស់។<br><br>ឧទាហរណ៍ ការប្រមូលទិន្នន័យពីរបៀបដែលស្ត្រី និងបុរសជាច្រើន ពឹងអាស្រ័យលើធនធានទន្លេមេគង្គដោយផ្ទាល់ គឺជាការប្រមូលទិន្នន័យតាមភេទដ៏សាមញ្ញ។ ផ្ទុយមកវិញ ការប្រមូលទិន្នន័យយេនឌ័រ នឹងរួមបញ្ចូលកត្តាផ្សេងៗបន្ថែមទៀត ដែលកំណត់ភាពខុសគ្នារវាង 'ការពឹងអាស្រ័យ' បន្ថែម (ឧ.ការវិភាគទិន្នន័យបែបអន្តរវិស័យ) រួមមានអាយុ ស្ថានភាពទំនាក់ទំនងក្នុងសហគមន៍ លក្ខខណ្ឌសេដ្ឋកិច្ច ការទទួលបានការអប់រំ ជាតិសាសន៍ អត្តសញ្ញាណយេនឌ័រ ពិការភាព និងកត្តាផ្សេងៗ ដែលជះឥទ្ធិពលលើសមត្ថភាពបុគ្គលម្នាក់ ក្នុងនាមជាអ្នករួមវិភាគទានដ៏សកម្ម នៅក្នុងកិច្ចការអភិបាលកិច្ចទឹក និងទទួលបានប្រយោជន៍ដោយសមធម៌ពីធនធានទឹក។ ដូច្នេះ ទិន្នន័យយេនឌ័រ ត្រូវបានជំរុញយ៉ាងខ្លាំងដោយបរិបទ និងតម្រូវការទៅតាមផ្នែក។ ជាទូទៅ គោលការណ៍នេះ អាចអនុវត្តបាន ប្រសិនបើគេមានគោលដៅផ្សព្វផ្សាយដល់ក្រុមប្រជាជនដែលមានការប្រមូលផ្តុំខ្លាំងបំផុតនៃឧបសគ្គតាមអន្តរវិស័យ ហើយមិនមាននរណាម្នាក់ត្រូវបានគេបោះបង់ចោលនោះទេ។<br><br>សូចករយេនឌ័រដែលមានអត្ថន័យ ថ្លឹងថ្លែងពីទិដ្ឋភាពផ្សេងៗដែលបានលើកឡើង ពីខាងលើនេះ។ ជាថ្មីម្តងទៀត បរិបទ គឺជាអ្នកសម្រេចចិត្តក្នុងការបង្កើតឲ្យមាននូវសូចនាករដែលមានប្រសិទ្ធភាព ពោលគឺវិធីដែលយើងវាស់វែងការផ្លាស់ប្តូរសម្រាប់ក្រុមខុសៗគ្នា ទៅតាមមធ្យោបាយដែលបង្ហាញថាគោលនយោបាយ យុទ្ធសាស្ត្រ ឬសកម្មភាពមួយ មានប្រសិទ្ធភាព ឬអត់? បន្ថែមពីលើសូចនាករបែបបរិមាណវិស័យ (យោងលើស្ថិតិ ដែលបំបែកទៅតាមភេទ) វាអាចនឹងមានសូចនាករបែបគុណវិស័យ (យោងលើបទពិសោធន៍ ឥរិយាបទ ទស្សនៈ និងអារម្មណ៍របស់ស្ត្រី និងបុរស)។ សូចនាករដែលពិចារណាពីយេនឌ័រ ផ្តល់លទ្ធភាពឲ្យមានការវាស់វែងពីការផ្លាស់ប្តូរនានានៅក្នុងទំនាក់ទំនងរវាងស្ត្រី និងបុរសក្នុងមុខងារគោលនយោបាយ កម្មវិធី ឬសកម្មភាពជាក់ស្តែងមួយ ក៏ដូចជាការប្រែប្រួលពីស្ថានភាព ឬឋានៈរបស់ស្ត្រី និងបុរស។<br><br>ជាថ្មីម្តងទៀត ប្រសិនបើវិធីសាស្ត្រទ្វេភាគ (ស្ត្រី/បុរស) មិនអាចទទួលបានព័ត៌មានពី |

| | |
|---|---|
| | ការផ្លាស់ប្តូរឲ្យបានគ្រប់គ្រាន់ទេ វាចាំបាច់ណាស់ក្នុងការដាក់បញ្ចូលនូវសមាសធាតុ 'អត្តសញ្ញាណយេនឌ័រ' ទៅក្នុងការតាមដាន និងការវាយតម្លៃ។ |

## អភិក្រមណែនាំនៃការបញ្ជ្រាបយេនឌ័ររបស់ MRC

អភិក្រមណែនាំ ដែលបានលើកឡើងនៅក្នុងឯកសារ[13]គោលនយោបាយស្តីពីយេនឌ័ររបស់ MRC រួមមាន៖

- សមភាព និងសមធម៌យេនឌ័រ ត្រូវបានចាត់ទុកជាកិច្ចការស្នូលមួយនៃមុខងារ និងសកម្មភាពទាំងអស់របស់ MRC។
- ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធក្នុងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ ទាមទារឲ្យមានការទទួលស្គាល់ថា រាល់សកម្មភាពរបស់ MRC មានឥទ្ធិពលខុសៗគ្នាលើស្ត្រី និងបុរស ហើយថា ទស្សនាទាន តម្រូវការ ចំណាប់អារម្មណ៍ តួនាទី និងធនធានរបស់ស្ត្រី និងបុរស គប្បីត្រូវបានគេពិចារណានៅគ្រប់ដំណាក់កាលទាំងអស់។
- សមភាព និងសមធម៌យេនឌ័រ គឺជាគុណតម្លៃមូលដ្ឋាន ដែលចាំបាច់ត្រូវពង្រឹង និងឆ្លុះបញ្ចាំងនៅក្នុងជម្រើសអភិវឌ្ឍន៍នានា និងការអនុវត្តតាមស្ថាប័ន។

ថ្នាក់ដឹកនាំ និងអ្នកគ្រប់គ្រង MRC ប្តេជ្ញាចិត្តជំរុញលើកកម្ពស់សមភាពយេនឌ័រដោយបុរេសកម្ម ទាំងនៅក្នុងស្ថាប័ន និងសម្រាប់កិច្ចការទាំងមូលរបស់ MRC។

ស្មារតីនេះ ស្របទៅនឹងការប្តេជ្ញាចិត្តថ្នាក់តំបន់ និងអន្តរជាតិ ក្នុងការជំរុញឲ្យមានសមភាពយេនឌ័រ៖

- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព[14] ជាពិសេសចំណុចគោលដៅទី៥.៥ (ការដឹកនាំ និងការចូលរួមរបស់ស្ត្រី) ទី៥គ (គោលនយោបាយនានា ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី) ទី៨.៥ (ការបម្រើការងារពេញលេញ និងដោយផលិតកម្ម និងមានប្រាក់កម្រៃស្មើគ្នា) ទី១០.២ (លើកកម្ពស់បរិយាបន្ន) ទី៦.១ (ការទទួលបានទឹកប្រើប្រាស់ដោយសមធម៌) និងទី៦.ខ (ការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងទឹក)
- **ភិក្រមឌូប្លីន-រីអូ (Dublin-Rio Principles) ស្តីពីការគ្រប់គ្រងធនធានទឹកតាមបែបចម្រុះ**[15]៖

---

[13] សូមមើលគណៈកម្មការទន្លេមេគង្គ (២០១៣)។

[14] គោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំងអស់៖ អង្គការសហប្រជាជាតិ, នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម (គ្មានកាលបរិច្ឆេទ)

[15] ភាពជាដៃគូស្តីពីទឹកជាសាកល (ជតស, ១៩៩៦)។

អតិក្រមទី២ (*វិធីសាស្ត្របែបចូលរួម៖ ការគ្រប់គ្រង និងអភិវឌ្ឍន៍ទឹក គប្បីផ្អែកលើវិធីសាស្ត្របែបចូលរួម ដោយមានការចូលរួមពីអ្នកប្រើប្រាស់ អ្នករៀបចំផែនការ និងអ្នកបង្កើតគោលនយោបាយនៅគ្រប់កម្រិតទាំងអស់*) និងអតិក្រមទី៣ (*តួនាទីរបស់ស្ត្រី៖ ស្ត្រីដើរតួដ៏សំខាន់ក្នុងការផ្តល់ឲ្យ ការគ្រប់គ្រង និងថែគាំពារទឹក*)

- **ផែនការស្តីពីសហគមន៍សង្គម-វប្បធម៌អាស៊ាន សម្រាប់ឆ្នាំ២០២៥**[16]៖ ការកាត់បន្ថយភាពងាយរងគ្រោះ វិសមភាព និងវិសមធម៌ រួមទាំងនៅលើមូលដ្ឋានគ្រឹះនៃយេនឌ័រ ការទទួលបានធនធានដោយសមធម៌ និងការជំរុញឲ្យមានការចូលរួមពីសហគមន៍ក្នុងការគ្រប់គ្រង និងថែគាំពារបរិស្ថាន។

ហេតុដូច្នេះ MRC ប្តេជ្ញាចិត្តនឹងប្រើប្រាស់វិធីសាស្ត្រឆ្លើយតបនឹងយេនឌ័រដោយបុរេសកម្ម។ វិធីសាស្ត្រនេះរួមបញ្ចូលនូវការរៀបចំការវិភាគដ៏ល្អិតល្អន់មួយ ស្តីពីលក្ខខណ្ឌស្ថានភាព និងតម្រូវការនៃក្រុមប្រជាជនខុសៗគ្នាក្នុងតំបន់អាងទន្លេមេគង្គ ផលវិបាកនៃយេនឌ័រ និងភាពងាយរងគ្រោះលើការរៀបចំផែនការ និងការអនុវត្តយន្តការគាំទ្រ និងផលប៉ះពាល់នៃយន្តការទាំងនេះលើក្រុមប្រជាជនផ្សេងគ្នា។ ការវិភាគ និងប្រមូលទិន្នន័យ នឹងផ្តោតជាចំបងលើការកំណត់អត្តសញ្ញាណវិសមភាពនៃស្ត្រី និងបុរសក្នុងស្ថានភាពខុសៗគ្នា ពាក់ព័ន្ធនឹងការប្រើប្រាស់/ទទួលផលប្រយោជន៍ពីធនធានពាក់ព័ន្ធទឹក។

ការបញ្ជ្រាបយេនឌ័រ មានទិដ្ឋភាពចម្រុះ ដែលភាគច្រើនត្រូវបានគេគ្របដណ្តប់នៅក្នុងឯកសារជំនួយ និងផែនការសកម្មភាពបច្ចុប្បន្នស្តីពីយេនឌ័រ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង និងផែនការយុទ្ធសាស្ត្ររបស់ MRC។ ឯកសារជំនួយនេះ នឹងគ្របដណ្តប់ទិដ្ឋភាពភាគច្រើន យោងទៅតាមតំបន់មុខងារស្នូលរបស់ MRC។ រូបភាពខាងក្រោមនេះ បង្ហាញពីទិដ្ឋភាពរួមមួយនៃសមាសធាតុនានាសម្រាប់ការបញ្ជ្រាបយេនឌ័រ។[17]

[16] សូមមើលអាស៊ាន (២០១៦)។

[17] ដកស្រង់ចេញពី EIGE (២០២០ខ) ស្តីពីនិយមន័យនៃការបញ្ជ្រាបយេនឌ័រ




ទិដ្ឋភាពរួមពីវិធីបញ្ជ្រាបយេនឌ័រ

*សម្គាល់៖* សមភាពយេនឌ័រ មិនដូចគ្នានឹងភាពស្មើគ្នានៃយេនឌ័រទេ។ ដូច្នេះ ការលើកកម្ពស់ភាពតាងស្មើៗគ្នានៃស្ត្រី និងបុរសនៅក្នុង MRC មិនសំដៅលើការសម្រេចឲ្យបាននូវសមាមាត្រ ៥០/៥០ សម្រាប់បុគ្គលិកស្ត្រី និងបុរសទេ ប៉ុន្តែវាលើកទឹកចិត្តឲ្យថ្នាក់ដឹកនាំ ជំរុញឲ្យមានឱកាសស្មើៗគ្នានៅកម្រិតគ្រប់គ្រង កាលានុវត្តន៍តែងតាំងដោយមានតុល្យភាព និងយន្តការសម្រាប់ការចូលរួម និងការសម្រេចចិត្ត។

# ការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការរៀបចំផែនការគាំពារ និងដំណើរការនានា

ជំពូកនេះ ផ្តល់ព័ត៌មានស្តីពីការណែនាំទូទៅពីការបញ្ជ្រាបសមាសធាតុយេនឌ័រ និងភាពងាយរងគ្រោះ នៅក្នុងនីតិវិធី និងដំណើរការនៃការរៀបចំផែនការ ដោយផ្តោតលើការធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍន៍គោលការណែនាំផ្នែកយុទ្ធសាស្ត្រ និងបច្ចេកទេសសម្រាប់អាងទន្លេទាំងមូល។

- *ការរៀបចំផែនការថ្នាក់តំបន់រួម យុទ្ធសាស្ត្រវិស័យថ្នាក់តំបន់ ការបង្កើត និងការវាយតម្លៃសេណារីយ៉ូអភិវឌ្ឍន៍បែបជម្រើស និងការរៀបចំផែនការគ្រប់គ្រងកំណកករសម្រាប់អាងទន្លេទាំងមូល។* ដំណើរការនេះ រួមមានការកំណត់អត្តសញ្ញាណគម្រោងវិនិយោគរួមថ្មីៗ និងគម្រោងថ្នាក់ជាតិសម្រាប់សារៈសំខាន់អាងទន្លេទាំងមូល ដែលអាចបង្កើនសហថាមពល និងកាត់បន្ថយការដោះដូររវាងសេដ្ឋកិច្ច និងបរិស្ថាន និងភាពងាយរងគ្រោះ ទាំងនៅកម្រិតអាងទន្លេ និងថ្នាក់ជាតិ និងផ្តល់នូវការឆ្លើយតបយ៉ាងទូលំទូលាយមួយ ទៅនឹងការប្រែប្រួលអាកាសធាតុ និងបញ្ហាប្រឈមពាក់ព័ន្ធនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត (ឧ. ការអភិវឌ្ឍអាងស្តុកពហុបំណងនៅផ្នែកខាងលើទន្លេ ការគ្រប់គ្រងទឹកជំនន់នៅផ្នែកខាងក្រោមទន្លេ និងការប្រើប្រាស់ទឹក)។
- គោលការណ៍ណែនាំស្តីពីការអនុវត្តប្រសើរបំផុត និងការណែនាំពីការអនុវត្តកម្មវិធី និងគម្រោងរួមគ្នានៅកម្រិតថ្នាក់ជាតិដែលបានពន្យាពេល និងមានស្រាប់ ដើម្បីកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ និងហានិភ័យឆ្លងដែនដែលអាចកើតមាន។
- ការត្រួតពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពនៃនីតិវិធី MRC ដោយផ្តោតលើរយៈពេលអនុវត្តយុទ្ធសាស្ត្រនេះ ពោលគឺនីតិវិធីសម្រាប់ថែទាំរំហូរលើទន្លេមេ (PMFM) និងនីតិវិធីសម្រាប់គុណភាពទឹក (PWQ)។

## ការណែនាំ និងឧបករណ៍បញ្ជ្រាបយេនឌ័រ

| ដំណើរការ | សំណួរសំខាន់ៗ | ឧបករណ៍/វិធីសាស្ត្រ |
|---|---|---|
| **ត្រួតពិនិត្យឡើងវិញនូវនីតិវិធី និងគោលការណ៍ណែនាំបច្ចេកទេសរបស់ MRC** | តើនីតិវិធីបច្ចុប្បន្ន បានពិចារណាគ្រប់ជ្រុងជ្រោយពីផលប៉ះពាល់នានា ដូចជាគុណភាពទឹក រំហូរទឹក ជលផល លើស្ថានភាពសង្គម និងភាពងាយរងគ្រោះរបស់ស្ត្រី និងបុរសដែរឬទេ? | **ការពិនិត្យឡើងវិញ និងការប្រើប្រាស់វិធីសាស្ត្រ ឧបករណ៍ និងភាសាដែលប្រើប្រាស់** សំដៅធានាថា នីតិវិធី/យុទ្ធសាស្ត្រ បានគ្របដណ្តប់ផលប៉ះពាល់សង្គម រួមទាំងភាពខុសគ្នាតាមយេនឌ័រ (ឧ. តើគុណភាពទឹកប៉ះពាល់ដល់សុខភាព ឬសម្ពាធពេលវេលារបស់ស្ត្រី និងបុរស ខុសគ្នាយ៉ាងដូចម្តេចខ្លះ?)។ ជាទូទៅ ការត្រួតពិនិត្យឡើងវិញ បានរៀបចំឡើងតាម |

| | | |
|---|---|---|
| | | រយៈការត្រួតពិនិត្យលើឯកសារស្រាវជ្រាវពីមុនៗ។ ពេលដែល MRC មិនមានទិន្នន័យ បទពិសោធន៍ពី<br>បណ្តាលអាងទន្លេផ្សេងៗ អាចនឹងមាន។ នៅពេលដែលគ្មានទិន្នន័យ ការប្រមូល/វិភាគទិន្នន័យ គប្បីចាប់ផ្តើមអនុវត្តជាផ្នែកមួយនៃដំណើរការរៀបចំគម្រោង/ធ្វើបច្ចុប្បន្នភាព។ |

| | | |
|---|---|---|
| | តើយើងមានទិន្នន័យតាមភេទ និងស្ថិតិយេនឌ័រគ្រប់គ្រាន់ ដើម្បីធ្វើបច្ចុប្បន្នភាព និងពិនិត្យតាមដាននីតិវិធីដែរឬទេ? | **ការកំណត់គម្លាតទិន្នន័យ និងត្រួតពិនិត្យឡើងវិញនូវជម្រើសផ្សេងៗ** ដើម្បីប្រមូលទិន្នន័យដែលត្រូវការ។ ការផ្សារភ្ជាប់ដោយមានប្រសិទ្ធភាពនូវលទ្ធផលពីសកម្មភាពផ្សេងៗ (ពីការវាយតម្លៃលើដែនកំហិតនៃការផ្លាស់ប្តូរសម្រាប់ធនធានបរិស្ថាន ការវិភាគលើយេនឌ័រ និងភាពងាយរងគ្រោះ ការប្រមូលទិន្នន័យយេនឌ័រ និងភាពងាយរងគ្រោះ និងការរៀបចំបង្កើតចក្ខុវិស័យភាពងាយរងគ្រោះ និងប្រព័ន្ធគាំពារការសម្រេចចិត្ត)។ ដើម្បីអាចធ្វើការវាយតម្លៃលើភាពងាយរងគ្រោះ និងផលប៉ះពាល់ ព័ត៌មានខាងក្រោមនេះ មានសារៈសំខាន់ណាស់ ក្នុងនោះរួមមាន៖ តើនរណាខ្លះដែលរងផលប៉ះពាល់ និងប៉ះពាល់ដូចម្តេចខ្លះ? តើនរណាខ្លះបានចូលរួមចំណែក និងតាមមធ្យោបាយអ្វីខ្លះ? ចំណុចលម្អិតជាច្រើន ខុសៗគ្នាទៅតាមប្រធានបទ។ |
| | តើយើងធ្វើដូចម្តេច ដើម្បីឲ្យមានការចូលរួមពីក្រុមប្រជាជនខុសៗគ្នា? | **ត្រួតពិនិត្យឡើងវិញនូវយន្តការចូលរួមរបស់សហគមន៍ដែលមានស្រាប់ និងបានគ្រោងទុក និងកំណត់ពីទំនាក់ទំនងផ្សេងៗដែលមានប្រសិទ្ធភាព** (ឧ. ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងវេទិកាភាគីពាក់ព័ន្ធថ្នាក់តំបន់ ដើម្បីតាងឲ្យសំលេងមូលដ្ឋាន ពាក់ព័ន្ធនឹងការប្រែប្រួលក្នុងរំហូរ និងគុណភាពទឹក)។ **ធ្វើបច្ចុប្បន្នភាពសកម្មភាពជូនដំណឹង និងការគ្រប់គ្រង** ដើម្បីធានាឲ្យមានការប្រាស្រ័យទាក់ទងពេលវេលា ជាមួយនឹងសហគមន៍រងគ្រោះ ក្នុងករណីអាសន្ន ឬការផ្លាស់ប្តូរចាំបាច់ដែលប៉ះពាល់ដល់ជីវភាពរបស់ពួកគេ។ (សូមមើលទំព័រទី២៤ សម្រាប់ព័ត៌មានលម្អិតស្តីពីការប្រាស្រ័យទាក់ទងជាមួយនឹងភាគីពាក់ព័ន្ធ)។ |

| | | |
|---|---|---|
| **ការអភិវឌ្ឍ/ធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំ និងការណែនាំសម្រាប់គម្រោងថ្នាក់ជាតិ ឬគម្រោងរួម ផែនការគ្រប់គ្រង និងយុទ្ធសាស្ត្រ និងផែនការវិស័យថ្នាក់តំបន់នានា** | តើយើងបានដឹងអ្វីខ្លះពីផលប៉ះពាល់នៃ XX( ការផ្តោតលើគោលការណ៍ណែនាំ/គម្រោង ឧ. វិធីសាស្ត្រប្រមូលទិន្នន័យសម្រាប់កម្មវិធីតាមដានបរិស្ថានចម្រុះ ) លើស្ត្រី និងបុរសក្នុងតំបន់រងគ្រោះ ? តើយើងដឹងអ្វីខ្លះពីវិភាគទានរបស់ពួកគេចំពោះ XX ( ឧ. ការតាមដានគុណភាពទឹក ) ? | **ការត្រួតពិនិត្យឡើងវិញ និងការដាក់បញ្ចូលនូវ** ទិន្នន័យតាមភេទដែលមានស្រាប់ និងព័ត៌មានយេនឌ័រពាក់ព័ន្ធនឹងប្រធានបទជាក់លាក់ ( ករណីសិក្សា ទិន្នន័យជំរឿន របាយការណ៍ដៃគូអភិវឌ្ឍន៍ )។ ការវិភាគ និងសិក្សាស្រាវជ្រាវដែលបានគ្រោងទុក ( ការសិក្សាពីយេនឌ័រ និងភាពងាយរងគ្រោះ ការវិភាគពីធនធានបរិស្ថាន ការរៀបចំបង្កើតចក្ខុវិស័យភាពងាយរងគ្រោះ ) គប្បីអាចបង្កើតបាននូវទិន្នន័យសំខាន់កាន់តែច្រើន នាពេលអនាគត។ កិច្ចការទាំងនេះ គប្បីរួមបញ្ចូលទាំងភាពងាយរងគ្រោះ និងកាលានុវត្តន៍នានា ដូចជាទីភ្នាក់ងារផ្លាស់ប្តូរដែលមានសក្តានុពល ផ្តួចផ្តើមការផ្លាស់ប្តូរក្នុងរយៈពេលវែង ? |
| | តើយើងខ្វះព័ត៌មានអ្វីខ្លះ ដើម្បីវាយតម្លៃផលប៉ះពាល់ដែលអាចកើតមានលើស្ត្រី និងបុរសក្នុងតំបន់រងគ្រោះ ? ប្រសិនបើមិនមានទិន្នន័យពាក់ព័ន្ធនឹងទន្លេមេគង្គ តើវាមានការអនុវត្តប្រសើរបំផុត/បទពិសោធន៍ផ្សេងៗពីអាងទន្លេផ្សេងៗ/អង្គការអាងទន្លេថ្នាក់តំបន់ដែរឬទេ ? ប្រសិនបើចាំបាច់ត្រូវបង្កើតទិន្នន័យ តើនរណាជាអ្នកអនុវត្តតាមវិធីណាខ្លះ ហើយត្រូវចំណាយអស់ប៉ុន្មាន ? | ការដោះស្រាយគម្លាតទិន្នន័យៈ<br><br>**ស្នើសុំធ្វើការវិភាគមួយ** រៀបចំដោយប្រទេសជាសមាជិក ដៃគូខាងក្រៅ (អង្គការសង្គមស៊ីវិលតាមមូលដ្ឋាន អ្នកប្រឹក្សាយោបល់) ឬដៃគូអភិវឌ្ឍន៍ផ្សេងៗ។<br><br>**ការស្វែងរកមតិរបស់ MRC** ដោយប្រើប្រាស់បណ្តាញផ្ទៃក្នុង ( ឧ. អង្គការសង្គមស៊ីវិលដែលសកម្មក្នុងវេទិកាភាគីពាក់ព័ន្ធថ្នាក់តំបន់ ឬកិច្ចប្រជុំផ្តល់ព័ត៌មានតាមគោលដៅក្នុងវេទិកាទាំងនេះ )។<br><br>ប្រសិនបើគេត្រូវការទិន្នន័យ ក្នុងករណីមានអាសន្ន គេអាចទទួលបានមូលនិធិផ្សេងៗពី**យន្តការមូលនិធិទន្លេមេគង្គ**ដែលបានគ្រោងទុក ( ឧ. ការវាយតម្លៃរហ័សពីផលប៉ះពាល់ផ្នែកសុខភាពលើសហគមន៍នានា បន្ទាប់ពីមានការលេចធ្លាយនូវសារធាតុពុល )។<br><br>ប្រសិនបើការវិភាគមិនអាចអនុវត្តបានទេ គេក៏គួរ |

| | | |
|---|---|---|
| | | តែបន្តលើកឡើងពីសមាសធាតុយេនឌ័រ និងភាពងាយរងគ្រោះនៅក្នុងគោលការណ៍ណែនាំ ដើម្បី **ទាក់ទាញការយល់ដឹងពីគម្លាតចំណេះដឹងទូទៅ និងស្វែងរកដំណោះស្រាយរួមគ្នា**។ ប្រសិនបើមាន បទពិសោធន៍ និងការអនុវត្តប្រសើរបំផុតពីខាងក្រៅតំបន់ទន្លេមេគង្គ អាចនឹងត្រូវបានគេប្រើប្រាស់ ដើម្បីទាញយកការសន្និដ្ឋានបឋមពីផលប៉ះពាល់យេនឌ័រខុសៗគ្នានៃ កក។ |
| | តើយើងអាចដោះស្រាយបញ្ហាវិសមភាពយេនឌ័រ និងភាពងាយរងគ្រោះក្នុង កក (ការណែនាំ ការរៀបចំគម្រោង) បានដោយរបៀបណាខ្លះ? | ការកាត់បន្ថយវិសមភាព និងភាពងាយរងគ្រោះទាមទារឲ្យយើងដឹងពីបុព្វហេតុនៃបញ្ហាទាំងពីរនេះ។ ដូច្នេះ លទ្ធភាពនៃទិន្នន័យតាមផ្នែក មានភាពចាំបាច់ណាស់ក្នុងការកំណត់ពីវិធានការអនុវត្ត។ ក៏ប៉ុន្តែ វិសមភាព និងភាពងាយរងគ្រោះខ្លះ ត្រូវបានគេសន្និដ្ឋានថាមានលក្ខណៈជាសកល ហើយជាទូទៅ វាទាមទារឲ្យមានការត្រិះរិះពិចារណា នៅពេលផ្តល់ការណែនាំ ឧ. ជាទូទៅ ស្ត្រីទទួលបាន និងប្រើប្រាស់ធនធានទ្រព្យសម្បត្តិ និងផលប្រយោជន៍នានាតិចជាង ហើយភាគច្រើន ទទួលរងសម្ពាធខ្លាំងជាង នៅក្នុងកិច្ចការដែលមាន និងគ្មានប្រាក់កម្រៃ។ ឧទាហរណ៍ គ្រោះរាំងស្ងួតក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បង្កឲ្យមានមហន្តរាយសុខភាព តាមរយៈការកាត់បន្ថយបរិមាណទឹកដែលមានសម្រាប់ពិសារ ការចំអិនអាហារ និងអនាម័យ និងតាមរយៈសន្តិសុខស្បៀងអាហារ។<br><br>ស្ត្រី និងសូម្បីតែកុមារី (និងកូនៗរបស់គេ) រងគ្រោះជាវិសមាមាត្រពីកង្វះអាហារូបត្ថម្ភ និងសម្ពាធទាក់ទិននឹងការធ្វើដំណើរយ៉ាងឆ្ងាយដើម្បីទៅយកទឹក។ ផ្ទុយមកវិញ ទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ វាមានភស្តុតាងបង្ហាញថា គ្រោះរាំងស្ងួតអាចបង្កើនជាវិសមា |

| | | |
|---|---|---|
| | | មាត្រនូវអត្រាធ្វើអត្តឃាត ក្នុងចំណោមកសិករបុរស។[18] ផលប៉ះពាល់ពាក់ព័ន្ធនឹងយេនឌ័រទាំងនេះ អាចត្រូវបានដោះស្រាយ នៅក្នុងគោលការណ៍ណែនាំ និងការប្រឹក្សាយោបល់ជាមួយនឹង ៖ (ក) ការកាត់បន្ថយហានិភ័យដោយពិចារណាពីយេនឌ័រ/យន្តការ'មិនបង្កើតហានិភ័យ' (ខ) យន្តការឆ្លើយតបនឹង<br>យេនឌ័រ (ឧ. ការគាំទ្រឲ្យផ្សារភ្ជាប់គម្រោងគ្រោះរាំងស្ងួតរួម ជាមួយនឹងគម្រោងសន្តិសុខអាហារូបត្ថម្ភ និងការទទួលបាន និងប្រើប្រាស់ជង្រុកស្រូវរួម/ផែនការឥណទានពេលអាសន្នដែលមានហានិភ័យទាព/ប្រភពចំណូលផ្សេងៗ ដើម្បីធានាសុវត្ថិភាពជីវភាពរស់នៅ)។<br><br>នៅក្នុងការវាយតម្លៃ និងរៀបចំផែនការទាំងនេះ វានឹងនាំឲ្យមានការកំណត់ពីទីភ្នាក់ងារផ្លាស់ប្តូរ នៅក្នុងក្រុមគោលដៅ ដើម្បីគាំពារដល់ការផ្លាស់ប្តូរផ្នែកឥរិយាបទ និងសង្គម។ |
| | តើនរណាអាចអនុវត្តយន្តការដែលបានស្នើ ហើយតើគេអាចទទួលបានហិរញ្ញប្បទានបានដោយរបៀបណា? | ដោយដាក់បន្ថែមពីលើខ្លឹមសារ ការណែនាំណាមួយក៏ត្រូវតែ **ឆ្លើយតបនឹងទំនួលខុសត្រូវ និងជម្រើសធនធានផ្សេងៗ សំដៅធានាឲ្យមានការអនុវត្តយន្តការដែលបានស្នើ**។ នៅពេលក្រុមការងារជំនាញចម្រុះ ចូលរួមរៀបចំផែនការគម្រោង/យន្តការណែនាំ **មន្ត្រីឯកទេសម្នាក់ផ្នែកផលប៉ះពាល់សង្គម/យេនឌ័រ និងភាពងាយរងគ្រោះ** នឹងទទួលបន្ទុកជួយសម្របសម្រួលករណីកិច្ច និងធនធាននានា។ **មន្ត្រីអនុវត្តផ្នែកយេនឌ័រថ្នាក់ជាតិ** តាមបណ្តាលប្រទេសជាសមាជិក នៅកម្រិតក្រសួង អាចដើរតួនាទីមន្ត្រីសម្របសម្រួលធ្វើការកំណត់បុគ្គលិក/ស្ថាប័នសំខាន់ៗ នៅក្នុងប្រទេស ឲ្យដឹកនាំយន្តការដាក់លាក់នានា។ |

[18] ឧទាហរណ៍ទាំងអស់នេះ បានមកពីអង្គការសុខភាពពិភពលោក (២០១៤) ស្តីពីយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងសុខភាព។

| | | |
|---|---|---|
| | | ជាញឹកញាប់ គម្រោងមានភាពសកម្មរួចទៅហើយ នៅតាមតំបន់គោលដៅ ដូច្នេះ **ការសម្រួលសម្រួល និងការផ្លាស់ប្តូរ** អាចនឹងរៀបចំបាន។<br><br>ដោយហេតុថាសមត្ថភាព**រៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ**តាមប្រទេសជាសមាជិកភាគច្រើន មានកម្រិតទាបនៅឡើយ សៀវភៅរបស់ MRC នេះលើកឡើងថា យន្តការមួយចំនួន អាចត្រូវការប្រភពមូលនិធិចម្រុះ (ឧ. ថ្នាក់ជាតិ ដៃគូអភិវឌ្ឍន៍ ឬមូលនិធិទន្លេមេគង្គ)។ |
| **ការបង្កើតសេណារីយ៉ូអភិវឌ្ឍន៍បែបជម្រើស** | តើមានវិសមភាព និងភាពងាយរងគ្រោះណាខ្លះ តាមក្រុមគោលដៅ នៅក្នុងសេណារីយ៉ូអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន? | **ការវិភាគស្ថានភាពដោយពិចារណាពីយេនឌ័រ និងភាពងាយរងគ្រោះ**៖ ត្រួតពិនិត្យឡើងវិញ និងដាក់បញ្ចូលគ្នានូវទិន្នន័យតាមភេទ និងព័ត៌មានពាក់ព័ន្ធយេនឌ័រដែលមានស្រាប់។ ជាពិសេស ព័ត៌មានពាក់ព័ន្ធនឹងការបែងចែកកម្លាំងពលកម្មតាមយេនឌ័រ នៅក្នុងសកម្មភាពពាក់ព័ន្ធធនធានទឹក, ឧបសគ្គ និងផលលំបាកសម្រាប់ស្ត្រី និងបុរស ក្នុងការប្រើប្រាស់ធនធានទឹក និងផលប្រយោជន៍ទាំងនេះ, និងទីភ្នាក់ងារផ្លាស់ប្តូរដែលអាចមាន។<br><br>ដូចគ្នាផងដែរ ធានាឲ្យមានការដាក់បញ្ចូលនូវព័ត៌មានដែលបង្កើតដោយសកម្មភាព MRC ផ្សេងៗទៀត (ឧ. ការវិភាគលើយេនឌ័រ និងភាពងាយរងគ្រោះ ការវិភាគពីដែនកំណត់នៃធនធានបរិស្ថាន និងការរៀបចំអភិវឌ្ឍចក្ខុវិស័យសម្រាប់ភាពងាយរងគ្រោះ)។ |

| | | |
|---|---|---|
| | តើយើងអាចជៀសវាងការបន្តនូវវិសមភាព និងភាពងាយរងគ្រោះដែលបានកំណត់បាន (មិនបង្កហានិភ័យ) ដោយរបៀបណា? និងតើមានសេណារីយ៉ូណាខ្លះ ដែលអាចលើកកម្ពស់សមភាពយេនឌ័រ និងកាត់បន្ថយភាពងាយរងគ្រោះបាន (វិធីសាស្ត្រឆ្លើយតបនឹងយេនឌ័រ និងភាពងាយរងគ្រោះ)? | **ការវាយតម្លៃពីតម្រូវការតាមយេនឌ័រ និងការវិភាគពីភាគីពាក់ព័ន្ធ**[19] អាចនឹងរៀបចំមួយផ្នែកតាមរយៈការសិក្សាស្រាវជ្រាវឯកសារពីមុនៗ និងមួយផ្នែកទៀត ដោយផ្អែកលើការប្រឹក្សាយោបល់របស់ភាគីពាក់ព័ន្ធ (ប្រទេសជាសមាជិក កិច្ចពិគ្រោះយោបល់របស់អង្គការសង្គមស៊ីវិលក្នុងអំឡុងវេទិកាភាគីពាក់ព័ន្ធថ្នាក់តំបន់ ការស្ទង់មតិក្រុមគោលដៅ ប្រសិនបើអាចអនុវត្តបាន)។ វាមានគោលបំណង កំណត់ពីឱកាសនានាជំរុញឲ្យមានការទទួល និងប្រើប្រាស់ធនធានទឹកឲ្យបានត្រឹមត្រូវ និងផលប្រយោជន៍នានានៃក្រុមប្រជាជនខុសៗគ្នា។<br><br>**ការវិភាគលើការបាត់បង់-ផលប្រយោជន៍** សម្រាប់សេណារីយ៉ូបែបជម្រើស គប្បីសំដៅរួមបញ្ចូលនូវការចំណាយ និង/ឬការបាត់បង់ផលប្រយោជន៍ដែលអាចកើតមាននៃវិសមភាពសង្គម ទៅតាមដែលអាចអនុវត្តបាន និងដាក់ស្នើសេណារីយ៉ូវិនិយោគដោយពិចារណាពីភាពងាយរងគ្រោះ (ឧ. ការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធគាំពារគ្រោះទឹកជំនន់បែបឆ្លើយតបនឹងភាពងាយរងគ្រោះ)។ សូចនាករសំខាន់ៗ សម្រាប់ការវិភាគលើការចំណាយ និង/ឬការបាត់បង់ អាចនឹងពាក់ព័ន្ធនឹងធនធានទឹក និងប្រយោជន៍របស់វា ហើយការគ្រប់គ្រង អាចមានសមភាព និងសមធម៌នៅក្នុងរបរការងារ ការសម្រេចចិត្ត សហគ្រិនភាព ការទទួលបានក្រេឌីត ការទទួលបានការអប់រំ និងការបែងចែកយេនឌ័រនៃកម្លាំងពលកម្ម (មាន និងគ្មានប្រាក់កម្រៃ)។[20] |

[19] តារាងបញ្ជីរមួយដ៏មានប្រយោជន៍សម្រាប់ការចូលរួមពីភាគីពាក់ព័ន្ធដោយសមធម៌ និងមានបរិយាបន្នក្នុងអភិបាលកិច្ចទឹក មាននៅ OECD (២០១៥) ជាពិសេសនៅទំព័រទី១៧៤។

[20] សូចនាករដែលមានប្រយោជន៍សម្រាប់ធ្វើការវាស់វែង មាននៅក្នុងការសិក្សាស្រាវជ្រាវដោយលោក Ferrant និង Kolev (២០១៦), Wodon និង de

## ការបញ្ជ្រាបនៅក្នុងទិន្នន័យ ការតាមដាន និងព្យាករណ៍

ជំពូកនេះ ផ្តល់ព័ត៌មានស្តីពីការណែនាំទូទៅ ពីវិធីដាក់បញ្ចូលសមាសធាតុយេនឌ័រ និងភាពងាយរងគ្រោះទៅក្នុងការប្រមូលទិន្នន័យ សកម្មភាពតាមដាន និងព្យាករណ៍ និងរបៀបប្រើប្រាស់ទិន្នន័យតាមផ្នែក។ ទិន្នន័យនេះ ផ្តោតលើការវិភាគលើបរចិញ្ចឹមជីវិតរបស់ប្រជាជនតាមដងទន្លេមេគង្គ ពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានពាក់ព័ន្ធទឹក និងផលប្រយោជន៍នានា។

| ដំណើរការ | សំណួរសំខាន់ៗ | ឧបករណ៍/វិធីសាស្ត្រ |
|---|---|---|
| **រៀបចំការសិក្សាស្រាវជ្រាវ/ការវាយតម្លៃ (ឧ. ការស្រាវជ្រាវពីចរាចរកំណកករ ការវាយតម្លៃពីដែនកំណត់នៃធនធានបរិស្ថាន)** | តើយើងដឹងអ្វីខ្លះពីផលប៉ះពាល់នៃ កក (ការសិក្សាស្រាវជ្រាវ/ការវាយតម្លៃលើប្រធានបទ ឧ.ការប្រែប្រួលនៃចរាចរកំណកករ) លើស្ត្រី និងបុរសនៅតាមសហគមន៍របស់ពួកគេ? តើយើងអាចកំណត់បានដែរឬទេ ថានរណាជាទីភ្នាក់ងារផ្លាស់ប្តូរ?) | **ត្រួតពិនិត្យឡើងវិញនូវទិន្នន័យតាមភេទ និងព័ត៌មានពាក់ព័ន្ធនឹងយេនឌ័រ** (ការផ្តល់អាទិភាពលើទិន្នន័យក្នុងតំបន់ទន្លេមេគង្គ ប៉ុន្តែបទពិសោធន៍ពីតំបន់ផ្សេងៗ ក៏មានប្រយោជន៍ក្នុងការកំណត់គម្លាតទិន្នន័យ និងទាញយកការសន្និដ្ឋានផ្សេងៗសម្រាប់ការសិក្សាស្រាវជ្រាវរបស់យើងផងដែរ)។<br><br>**កំណត់ព័ត៌មានពាក់ព័ន្ធសំខាន់ៗ** ដែលចាំបាច់សម្រាប់ដាក់បញ្ចូលយេនឌ័រ និងភាពងាយរងគ្រោះទៅក្នុងការរៀបចំការសិក្សាស្រាវជ្រាវ ដូចបានបង្ហាញក្នុងឧទាហរណ៍មួយនៃ***ការស្រាវជ្រាវពីចរាចរកំណកករ***។ ព័ត៌មានពាក់ព័ន្ធអាចរួមបញ្ចូលនូវផលប៉ះពាល់នៃបម្រែបម្រួលកករ និងសំណឹកតាមច្រាំងលើសន្តិសុខអាហារូបត្ថម្ភរបស់ស្ត្រី បុរស កុមារា និងកុមារី, សុខភាពប្រជាជន (ឧ. រងគ្រោះពីការបំពុលកករ) និងលើឱកាសចំណូលសម្រាប់ស្ត្រី និងបុរសក្នុងសហគមន៍តាមដងទន្លេមេគង្គ (ឧ. តាមផលប៉ះពាល់នៃសំណឹកច្រាំងលើការប្រើប្រាស់ដី)។ ការសិក្សាក៏អាចកំណត់ពីទីភ្នាក់ងារផ្លាស់ប្តូរដែរ។ ជាឧទាហរណ៍ ដោយសារជាទូទៅ ស្ត្រីជាអ្នកទទួលបន្ទុកលើអាហារូបត្ថម្ភប្រចាំគ្រួសារ យុទ្ធសាស្ត្រទំនាក់ទំនងគប្បីផ្តោតលើការជំរុញផ្សព្វផ្សាយយន្តការដាក់ |

la Brière (២០១៨), និង EIGE (២០១៦ខ)។

| | | |
|---|---|---|
| | | លាក់ដល់ក្រុមស្ត្រីក្នុងសហគមន៍ទាំងនេះ ដើម្បីទប់ស្កាត់ផលប៉ះពាល់សុខភាពអវិជ្ជមាននៃការបំពុលដែលបានកំណត់។ យន្តការផ្តោតលើគោលដៅទាំងនេះ អាចបង្កើតឲ្យមានឱកាសបន្ថែមទៀតសម្រាប់ការផ្តល់អំណាច ឧ. តាមរយៈការលើកកម្ពស់ឲ្យមានការបង្កើតក្រុមតាមដានស្ត្រី។<br><br>នៅពេលដែលការផ្តល់ព័ត៌មាន/ការប្រឹក្សាយោបល់ផ្ទាល់ជាមួយនឹងសហគមន៍រងគ្រោះ មានសារៈសំខាន់ (ឧ. នៅក្នុងការវាយតម្លៃពីដែនកំណត់នៃធនធានបរិស្ថាន) ការរៀបចំការសិក្សាស្រាវជ្រាវត្រូវតែបង្កើតឲ្យមាននូវយន្តការចូលរួម/ប្រឹក្សាយោបល់ដ៏មានប្រសិទ្ធភាព។ ឧទាហរណ៍ទាំងបី (ខាងក្រោម) សម្រាប់យន្តការដូច្នេះ (ប្រើប្រាស់ឧទាហរណ៍នៃការវាយតម្លៃពីដែនកំណត់នៃធនធានបរិស្ថាន) រួមមាន៖<br><br>(ក) នៅឯវេទិកាភាគីពាក់ព័ន្ធថ្នាក់តំបន់ កិច្ចប្រជុំបិទមួយ គប្បីដាក់បញ្ចូលជាមួយនឹងសហគមន៍ និងតំណាងមកពីអង្គការសង្គមស៊ីវិលពីតំបន់សំខាន់ដែលបានជ្រើសរើស (ឧ. តំបន់ដីសើមសំខាន់ៗ) ដើម្បីប្រមូលមតិយោបល់តាមមូលដ្ឋានពីដែនកំណត់នៃការផ្លាស់ប្តូរដែលអាចទទួលយកបាន។<br>(ខ) លេខាធិការដ្ឋាន MRC និងអង្គការសង្គមស៊ីវិល រៀបចំការវាយតម្លៃពីដែនកំណត់ក្នុងតំបន់ដែលបានជ្រើសរើស រួមទាំងបទសម្ភាសក្នុងសហគមន៍ និងដាក់ទិន្នន័យករណីសិក្សានេះទៅក្នុងការវាយតម្លៃរួម។<br>(គ) MRC គាំទ្រប្រទេសសមាជិកនីមួយៗ ឲ្យរៀបចំវេទិកាជជែកពិភាក្សាតាមមូលដ្ឋាន (ឧ. តាមតំណាងសភាថ្នាក់ខេត្ត និងថ្នាក់ជាតិ ដែលរៀបចំវេទិកាចូលរួមការបោះឆ្នោតតាមមូលដ្ឋាន |

| | | |
|---|---|---|
| | | ជាប្រចាំ) ឬផ្តល់ប្រាក់កម្រៃដល់ករណីសិក្សា (អនុវត្តដោយបុគ្គលិករដ្ឋបាលតាមមូលដ្ឋាន ឬ អង្គការសង្គមស៊ីវិល)។<br><br>សំណួរណែនាំសម្រាប់ឧទាហរណ៍ទាំងបី រួមមាន៖ តើនរណាខ្លះដែលរងផលប៉ះពាល់ ដោយរបៀបណា និងដោយការផ្លាស់ប្តូរបែបណា (ត្រង់នេះ៖ នៃប្រព័ន្ធបរិស្ថានដែលរងគ្រោះ)? តើនរណាខ្លះបានចូលរួមចំណែក និងតាមមធ្យោបាយអ្វីខ្លះ (ត្រង់នេះ៖ ដើម្បីការពារតំបន់ដីសើម)? តើការផ្លាស់ប្តូរ និងមិនផ្លាស់ប្តូរណាខ្លះ បានធ្វើឲ្យវិសមភាព និងភាពងាយរងគ្រោះកាន់តែអាក្រក់ឡើងបានយ៉ាងដូចម្តេច? |
| | តើព័ត៌មាននេះ ត្រូវបានប្រើប្រាស់ដោយរបៀបណា? | ការសិក្សាស្រាវជ្រាវ/ការវាយតម្លៃនីមួយៗ គប្បីកំណត់ពីឱកាសនានា សំដៅកាត់បន្ថយវិសមភាព និងភាពងាយរងគ្រោះក្នុងចំណោមសហគមន៍គោលដៅ។<br><br>នេះជាឧទាហរណ៍មួយស្តីពីការសិក្សាលើកំណកកករ ដែលមានគោលបំណងកំណត់នូវកាលានុវតន៍ដូចខាងក្រោមនេះ ពោលគឺ (ក) ធ្វើឲ្យប្រសើរឡើងនូវសន្តិសុខអាហារូបត្ថម្ភសម្រាប់សមាជិកក្នុងសហគមន៍ទាំងអស់ (ខ) សម្រាប់ប្រាក់ចំណូលផ្សេងទៀត ដើម្បីកាត់បន្ថយនូវការពឹងអាស្រ័យលើធនធានពាក់ព័ន្ធនឹងទឹក និង(គ) សម្រាប់យន្តការចូលរួមពីសហគមន៍ ដោយជៀបនឹងសំណឹកត្រឡប់វិញ (ប្រសិនបើអាច ជាមួយនឹងសមាសធាតុផ្តល់អំណាចមួយសម្រាប់តែងតាំងស្ត្រីជាអ្នកដឹកនាំក្នុងសហគមន៍ តួយ៉ាងការជំរុញភាពដឹកនាំរបស់ស្ត្រីក្នុងគណៈកម្មាធិការទប់ស្កាត់សំណឹកតាមមូលដ្ឋាន)។<br><br>តាមរយៈការកំណត់នូវកត្តាទាំងនេះ ដែនកំណត់ |

| | | |
|---|---|---|
| | | សង្គមដែលរារាំងដល់ការផ្លាស់ប្តូរ/យុទ្ធសាស្ត្រមិនបង្កហានិភ័យ និងឱកាសនានា ដើម្បីលើកកម្ពស់សមធម៌ និងកាត់បន្ថយភាពងាយរងគ្រោះ អាចត្រូវបានកំណត់សម្រាប់ក្រុមប្រជាជនផ្សេងៗគ្នា។<br><br>លទ្ធផលទទួលបានពីការវិភាគទាំងនេះ ក៏ត្រូវបានគេប្រើប្រាស់ផ្តល់ព័ត៌មានសម្រាប់ការវិភាគពីការចំណាយ/ការបាត់បង់សម្រាប់សេណារីយ៉ូអភិវឌ្ឍន៍បែបជម្រើសនានា សកម្មភាពរៀបចំបង្កើតចក្ខុវិស័យសម្រាប់ភាពងាយរងគ្រោះ យន្តការរៀបចំផែនការថ្នាក់តំបន់ យុទ្ធសាស្ត្រតាមវិស័យ និងការកំណត់អត្តសញ្ញាណ និងរៀបចំបង្កើតគម្រោងរួម និងគម្រោងថ្នាក់ជាតិនានា។ |
| **ការបង្កើតចក្ខុវិស័យសម្រាប់ភាពងាយរងគ្រោះ** | តើមានកត្តាអ្វីខ្លះ ដែលធ្វើឲ្យស្ត្រី និងបុរសតាមសហគមន៍ដងទន្លេ ស្ថិតក្នុងស្ថានភាពងាយរងគ្រោះ? | **ការវិភាគទិន្នន័យតាមផ្នែក និងព័ត៌មានពាក់ព័ន្ធយេនឌ័រ រួមទាំងការវិភាគពីគម្លាតនានា។**<br>សកម្មភាពបង្កើតចក្ខុវិស័យសម្រាប់ភាពងាយរងគ្រោះ គប្បីសំដៅលើការប្រមូលព័ត៌មានសំខាន់ៗដូចខាងក្រោមនេះ៖<br>• សហគមន៍ក្រីក្រ និងក្បែរក្រីក្ររស់ក្នុងតំបន់ធនធាន (ពាក់ព័ន្ធទឹក)បរិស្ថានសំខាន់ៗ (ឧ. យោងលើទិន្នន័យជំរឿនថ្នាក់ជាតិ និង GIS)<br>• ប្រក្រតីភាព និងភាពធ្ងន់ធ្ងរនៃគ្រោះមហន្តរាយពាក់ព័ន្ធទឹក/ហេតុការណ៍ចៃដន្យ និងរបៀបដែលព្រឹត្តិការណ៍ទាំងនេះ ជះឥទ្ធិពលលើក្រុមប្រជាជនខុសៗគ្នា ទាក់ទិននឹងសន្តិសុខទឹក ស្បៀងអាហារ និងថាមពល សុខភាព ប្រាក់ចំណូល និងរយៈពេលក្រីក្រ<br>• វិសមភាពអន្តរវិស័យក្នុងសហគមន៍នានា (ដាក់ចូលផ្ទាល់ទៅក្នុងសកម្មភាព ២.១.៤.៣ ឧ. អារម្មណ៍ជាម្ចាស់ជនជាតិភាគតិច, អត្រាអប់រំកម្រិតមធ្យមសិក្សា |

| | | |
|---|---|---|
| | | សម្រាប់ស្រី/ប្រុស, ការងារតាមវិស័យសម្រាប់ស្រី/ប្រុស, ភាពជាម្ចាស់កម្មសិទ្ធិដីធ្លីសម្រាប់ស្រី/បុរស, និងការទទួលបានឥណទានសម្រាប់ស្រី/ប្រុស)។ |
| | ការប្រើប្រាស់លទ្ធផលដែលទទួលបាន៖ តើការផ្លាស់ប្តូរ/វិនិយោគតាមវិស័យ រួមចំណែកដូចម្តេចខ្លះក្នុងការកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេ? | **ស្រទាប់**នៃទិន្នន័យទាំងនេះ នឹងផ្តល់នូវទិដ្ឋភាពលម្អិតមួយនៃភាពងាយរងគ្រោះ និងវិសមភាពក្នុងចំណោមសហគមន៍តាមដងទន្លេ។ វាក៏ផ្តល់នូវលទ្ធផលផ្សេងៗ សម្រាប់រៀបចំបង្កើតចក្ខុវិស័យ ដែលអាចត្រូវបានគេប្រើប្រាស់ជា**ព័ត៌មានសម្រាប់សកម្មភាពរៀបចំផែនការ ទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់**។ ឧទាហរណ៍ខ្លះៗ រួមមានការផ្តល់អាទិភាពសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធធន់នឹងគ្រោះទឹកជំនន់ ក្នុងតំបន់ដែលមានភាពងាយរងគ្រោះខ្លាំង, ការកំណត់អត្តសញ្ញាណសហគមន៍ដែលមានតម្រូវខ្លាំងបំផុត សម្រាប់ការប្រាស្រ័យទាក់ទងស្តីពីការជូនដំណឹងជាមុនឲ្យទាន់ពេលវេលា, និងការដាក់បញ្ចូលនូវភាពងាយរងគ្រោះដែលបានកំណត់ ទៅក្នុងសេណារីយ៉ូអភិវឌ្ឍន៍អាងទន្លេ។<br><br>គម្លាតទិន្នន័យដែលនឹងកំណត់ដោយការវិភាគ គប្បីត្រូវបានគេប្រើប្រាស់ជាមូលដ្ឋានគ្រឹះ **ទ្រទ្រង់ដល់ការប្រមូលទិន្នន័យដោយសុខដុមរមនីយ** ជាមួយនឹងគណៈកម្មាធិការជាតិទន្លេមេគង្គផ្សេងៗ។ ទោះបីជាភ្លាមៗ លទ្ធផលទាំងអស់នៃការរៀបចំបង្កើតចក្ខុវិស័យសម្រាប់ភាពងាយរងគ្រោះមិនទាន់មានក៏ដោយ **ការរៀបចំអភិវឌ្ឍប្រព័ន្ធគាំពារការសម្រេចចិត្ត** គប្បីបានពិចារណាលើការដាក់បញ្ចូលជាប្រព័ន្ធនូវព័ត៌មានខ្លះៗ ជាជំនួយសម្រួលដល់ដំណើរការធ្វើសមាហរណកម្ម នៅពេលដែលមានលទ្ធផលទាំងនេះ។ ការរៀបចំនេះ **យ៉ាងហោចណាស់ គប្បីដាក់បញ្ចូលនូវទិន្នន័យពី** |

| | | |
|---|---|---|
| | | **ភាពក្រីក្រ និងវិស័យតាមមុខរបរ (តាមយេនឌ័រ បើមាន)។**<br><br>ការអនុវត្តផែនការសកម្មភាពសម្រាប់ទទួល និងបង្កើតទិន្នន័យ (DAGAP) រួមទាំងការបែងចែកទិន្នន័យសង្គម និងសេដ្ឋកិច្ចទៅឲ្យ MRC ដែលប្រទេសជាសមាជិកមានរួចទៅហើយ នឹងកាន់តែមានតម្លៃខ្លាំងនៅក្នុងបរិបទនេះ។ |
| **សុខដុមនីយកម្មនៃទិន្នន័យតាមផ្នែកនៅថ្នាក់តំបន់** | តើទិន្នន័យប្រភេទណាខ្លះដែលចាំបាច់ ដើម្បីបង្កើតឲ្យបាននូវមូលដ្ឋានទិន្នន័យមួយសម្រាប់ស្ថិតិយេនឌ័រ ដែលយើងអាចដាក់ទៅក្នុងដំណើរការនៃការសម្រេចចិត្ត និងការរៀបចំផែនការខុសៗគ្នាបាន? | ទោះបីជាវាមានភាពចាំបាច់ ក្នុងការត្រួតពិនិត្យ និងសម្រួលតម្រូវការទិន្នន័យទៅតាមដំណើរការរៀបចំផែនការ/ការរចនា/ការអនុវត្តនីមួយៗក៏ដោយ ក៏វាមាន**មូលដ្ឋានទិន្នន័យរួម**មួយចំនួន ដែលអាចធ្វើឲ្យដំណើរការភាគច្រើនកាន់តែមានភាពប្រសើរ នោះគឺ៖<br>• ទិន្នន័យស្តីពីភាពក្រីក្រទៅតាមភេទ អាយុ ទីតាំង ក្រុមជនជាតិភាគតិច (រួមទាំងក្សែរក្រីក្រ ដែលមានសារៈសំខាន់ជាពិសេសនៅក្រោមស្ថានភាពអភិវឌ្ឍន៍ក្នុងអំឡុងពេលមានជំងឺរាលដាលកូវីដ១៩)<br>• ទិន្នន័យស្តីពីការទទួលបានទឹកស្អាត សន្តិសុខថាមពល និងស្បៀងអាហារ ទៅតាមភេទ អាយុ ទីតាំង និងក្រុមជនជាតិភាគតិច<br>• ទិន្នន័យមុខរបរផ្លូវការ និងក្រៅផ្លូវការ ពាក់ព័ន្ធនឹងធនធានទឹក និងជារួមសម្រាប់សហគមន៍តាមដងទន្លេ ដែលចាំបាច់ក្នុងការកំណត់នូវសក្តានុពលនានា ក្នុងការកាត់បន្ថយការពឹងអាស្រ័យរបស់សហគមន៍លើធនធានទឹក ដែលទិន្នន័យទាំងនេះ ត្រូវបានប្រមូលទៅតាមភេទ អាយុ ការទទួលបានការអប់រំ ទីតាំង និងក្រុមជនជាតិភាគតិច។<br><br>ការប្រមូលជាប្រព័ន្ធនូវទិន្នន័យទាំងនេះ នឹងចាំបាច់ត្រូវ**ដាក់បញ្ចូលទៅក្នុងផែនការចង្អុល** |

| | | |
|---|---|---|
| | | **បង្ហាញថ្នាក់ជាតិ** ( NIPs ) ព្រោះថាផែនការទាំងនេះ អាស្រ័យខ្លាំងលើសកម្មភាពថ្នាក់ជាតិ ដែលនឹងត្រូវអនុវត្ត។ ការចូលរួមពី**អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍**តាមមូលដ្ឋាន អាចក្លាយជាយន្តការមួយ គាំពារដល់ទីភ្នាក់ងារជាតិ ក្នុងការចាត់ចែងសកម្មភាពប្រមូលទិន្នន័យទាំងនេះ។ នៅកម្រិតអាស៊ាន វាមានភាពចាំបាច់ណាស់ ក្នុងការត្រួតពិនិត្យឲ្យបានទៀងទាត់នូវលទ្ធភាពទិន្នន័យថ្នាក់តំបន់ ឧ. ដែលបានប្រមូលដោយគណៈកម្មាធិការអាស៊ានពីស្ត្រី អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ ជីអាយហ្សិតច៍ និង/ឬអង្គការអន្តរជាតិអុកហ្វាម។ |
| **ការធ្វើឲ្យប្រើសើរឡើង និងសមាហរណកម្មនៃប្រព័ន្ធជូនដំណឹងជាមុន និងព្យាករណ៍គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់សម្រាប់អាងទន្លេទាំងមូល** | តើមានបណ្តាញទំនាក់ទំនងបច្ចុប្បន្នជាមួយនឹងសហគមន៍តាមមូលដ្ឋានណាខ្លះ ដែលរងផលប៉ះពាល់ដែលអាចកើតមានពីគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ ហើយវិធីណាដែលប្រសើរបំផុតដើម្បីប្រើប្រាស់បណ្តាញទាំងនេះឲ្យមានប្រសិទ្ធភាព និងល្អបំផុត ? | **ត្រួតពិនិត្យឡើងវិញនូវបណ្តាញទំនាក់ទំនងថ្នាក់ជាតិនាពេលបច្ចុប្បន្ន ជាមួយនឹង និងពីសហគមន៍រងគ្រោះតាមមូលដ្ឋាន៖** តើចំណេះដឹងរួមតាមមូលដ្ឋាន ( ឧ. ពីការផ្លាស់ប្តូរពាក់ពន្ធ័នឹងគ្រោះរាំងស្ងួតក្នុងទិន្នផលកសិកម្ម ការប្រែប្រួលកម្រិតទឹកភ្លាមៗ ឬជាបន្តបន្ទាប់ ) ត្រូវបានទទួល និងប្រើប្រាស់ដោយរបៀបណា ( ឧ. ព័ត៌មានពីកម្រិតមូលដ្ឋានទៅថ្នាក់ជាតិ ) ? តើគេប្រើប្រាស់បណ្តាញណាខ្លះដើម្បីផ្តល់ព័ត៌មានដល់សហគមន៍រងគ្រោះ ( ការព្យាករណ៍ និងការជូនដំណឹងជាមុន ) ហើយតើនរណាពិតប្រាកដ ដែលទទួលបានព័ត៌មានតាមការប្រាស្រ័យទាក់ទងទាំងនេះ ?<br><br>វាចាំបាច់ណាស់ ព្រោះថាបទពិសោធន៍អន្តរជាតិបង្ហាញថា ស្ត្រី និងបុរស ទទួលបាន ដំណើរការវិភាគបកស្រាយ និងឆ្លើយតបទៅនឹងព័ត៌មានខុសៗគ្នា ដោយសារកត្តាសង្គម និងវប្បធម៌នៃទំនាក់ទំនងយេនឌ័រ និងការបែងចែកពលកម្មការងារ[21]ទៅតាមយេនឌ័រ។ |

[21] សម្រាប់ឧទាហរណ៍ សូមមើល Brown និងអ្នកនិពន្ធផ្សេងៗ ( ២០១៩ ) ស្តីពីប្រពន្ធ័ជូនដំណឹងជាមុនដែលបានកែសម្រួលដោយផ្អែកលើយេនឌ័រ។

| | | |
|---|---|---|
| | តើយើងអាចរៀបចំបង្កើតយន្តការជូនដំណឹងជាមុនប្រកបដោយបរិយាបន្ន ដែលបានពិចារណាពីយេនឌ័រ បានយ៉ាងដូចម្តេច? | **ពង្រឹងប្រព័ន្ធជូនដំណឹងជាមុន ជាមួយនឹងយន្តការផ្តល់ដំណឹងជាមុនដែលពិចារណាពីយេនឌ័រ** ដែលគ្របដណ្តប់នូវចំណុចដូចខាងក្រោមនេះ៖[22]<br>**ក) ចំណេះដឹងពីហានិភ័យនៃភាពងាយរងគ្រោះ៖** ការវាយតម្លៃនានា ត្រូវដាក់បញ្ចូលនូវភាពងាយរងគ្រោះ និងសមត្ថភាពដែលមានជាក់លាក់សម្រាប់ទាំងស្ត្រី និងបុរស និងវាយតម្លៃពីហានិភ័យ ដែលក្រុមទាំងពីរនេះ បានប្រឈម ដោយថ្លឹងថ្លែងពីតួនាទី និងការទទួលខុសត្រូវ(ករណីកិច្ច)សង្គម និងសេដ្ឋកិច្ចផ្សេងៗគ្នា។<br>**ខ) ការតាមដានដោយបរិយាបន្ន៖** ប្រព័ន្ធនានា ដែលពិនិត្យតាមដាន កត់ត្រាទុក និងចែកចាយទិន្នន័យស្តីពីគ្រោះមហន្តរាយ និងភាពងាយរងគ្រោះសំខាន់ៗ រួមទាំងទិន្នន័យតាមភេទ និងការវិភាគលើបញ្ហាយេនឌ័រនានា។<br><br>មូលដ្ឋានទិន្នន័យថ្នាក់តំបន់ បញ្ជាំងឲ្យឃើញពីរចនាសម្ព័ន្ធនេះ ប្រើប្រាស់ទិន្នន័យតាមភេទ និងរួមបញ្ចូលលក្ខខណ្ឌរួម និងភាពផ្ទុយពីគ្នាផ្នែកសង្គម និងវប្បធម៌ ដើម្បីផ្តល់ជាជំនួយដល់ការរៀបចំផែនការសម្រាប់ការតាមដានឆ្លងដែននៃគ្រោះមហន្តរាយ និងភាពងាយរងគ្រោះនានា។<br><br>**គ) ការផ្សព្វផ្សាយការជូនដំណឹងជាមុនដោយមានអត្ថន័យដល់ក្រុមប្រជាជនដែលរងគ្រោះ៖** ការជូនដំណឹងជា |

[22] ការណែនាំលម្អិតដើម្បីរៀបចំបង្កើតប្រព័ន្ធជូនដំណឹងជាមុនឆ្លើយតបនឹងយេនឌ័រ មាននៅ UNISDR/UNDP/IUCN (២០១៩)។ លោកអ្នក ក៏អាចមើល Brown និងអ្នកនិពន្ធផ្សេងៗ (២០១៩) សម្រាប់ព័ត៌មានបន្ថែមពីប្រធានបទនេះ។

| | | |
|---|---|---|
| | | មុន ត្រូវបានគេបង្កើតឡើង និងផ្សព្វផ្សាយ ទន្ទឹមនឹងធានាថាស្ត្រី បុរស កុមារា និងកុមារីបានយល់ដឹងគ្រប់គ្រាន់ពីហានិភ័យទាំងនេះ និងទទួលបានការជូនដំណឹងទាន់ពេលវេលា។ គេផ្តល់ការយកចិត្តទុកដាក់ជាពិសេស ទៅតាមអាយុ វប្បធម៌ អក្ខរកម្ម ការទទួល និងប្រើប្រាស់ព័ត៌មាន និងបរិបទសង្គម-វប្បធម៌។ ប្រព័ន្ធប្រកាសអាសន្ន និងការជម្លៀស រួមមានយន្តការដាក់លាក់ ផ្សព្វផ្សាយដល់ស្ត្រី ដោយធានាឲ្យមានការឆ្លើយតបនឹងឧបសគ្គផ្នែកវប្បធម៌តាមយេនឌ័រណាមួយ លើការចល័ត និងលទ្ធភាពទទួលបានព័ត៌មាន។<br>**ឃ) សមត្ថភាពឆ្លើយតបរបស់សហគមន៍៖** ការវាយតម្លៃ ត្រូវបង្ហាញថា ស្ត្រី បុរស កុមារា និងកុមារី មានការយល់ដឹងពីគ្រោះមហន្តរាយដែលសហគមន៍កំពុងប្រឈម មានការប្រុងប្រយ័ត្នចំពោះសញ្ញាអាសន្នធម្មជាតិ ក៏ដូចជាការជូនដំណឹងជាមុនតាមផ្លូវការ និងដឹងពីរបៀបឆ្លើយតប។<br><br>ផែនការត្រៀមខ្លួន និងសមត្ថភាពឆ្លើយតប ត្រូវធ្វើសមាហរណកម្មលទ្ធផលវិភាគលើយេនឌ័រ និងដោះស្រាយភាពខុសគ្នាសំខាន់ៗ ដោយផ្អែកលើយេនឌ័រ នៅក្នុងការត្រៀមខ្លួន និងឆ្លើយតបនឹងគ្រោះហានិភ័យ។ |

## ការបញ្ជ្រាបនៅក្នុងការចូលរួមពីភាគីពាក់ព័ន្ធ និងការប្រាស្រ័យទាក់ទង

ជំពូកនេះ ផ្តល់ព័ត៌មានពីការណែនាំទូទៅពីវិធីធ្វើសមាហរណកម្មភាសាដែលពិចារណាពីយេនឌ័រ និងយន្ត

ការបញ្ជ្រាប នៅក្នុងការចូលរួមពីភាគីពាក់ព័ន្ធ និងយន្តការទំនាក់ទំនងរបស់ MRC។ វាផ្តោតលើតែយន្តការណា ដែលមិនបានគ្របដណ្តប់ក្រោមជំពូកមុនៗ តែប៉ុណ្ណោះ ព្រោះថា ដំណើរការភាគច្រើនរបស់ MRC ទាមទារឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធ និងកិច្ចសហប្រតិបត្តិការ (ឧ. ការរៀបចំបង្កើតគម្រោងរួម ការត្រួតពិនិត្យនីតិវិធីនានាឡើងវិញ ការធ្វើសុខដុមនីយកម្មទិន្នន័យ និងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធជូនដំណឹងជាមុននានា)។ ចាប់តាំងពីការបង្កើតនូវវេទិកាភាគីពាក់ព័ន្ធប្រកបដោយសុខដុមនីយកម្ម និងសម្រាប់អាងទន្លេទាំងមូល ដែលជាលទ្ធផលបានមកពីដំណើរការរួមគ្នាទាំងអស់ វិធីសាស្រ្តបញ្ជ្រាបនៅក្នុងសៀវភៅនេះ និងក្នុងផែនការសកម្មភាពស្តីពីយេនឌ័រដែលមានស្រាប់ បានផ្តល់នូវក្របខណ្ឌបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះសម្រាប់វេទិកានាពេលអនាគត។ សុខដុមនីយកម្មនៃទិន្នន័យតាមផ្នែកដែលបានពង្រឹង និងការដាក់បញ្ចូលជាប្រព័ន្ធនូវទិន្នន័យទាំងនេះទៅក្នុងដំណើរការរៀបចំផែនការ និងការសម្រេចចិត្ត គឺជាកិច្ចការស្នូលនៃការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះរបស់ MRC។

| ដំណើរការ | សំណួរសំខាន់ៗ | ឧបករណ៍/វិធីសាស្រ្ត |
|---|---|---|
| **ការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះ នៅក្នុងវេទិកាភាគីពាក់ព័ន្ធ កិច្ចប្រជុំប្រឹក្សាយោបល់ និងសិក្ខាសាលាពាក់ព័ន្ធនៅកម្រិតថ្នាក់តំបន់** | តើវាមានចំណុចចាប់ផ្តើមអ្វីខ្លះ ដើម្បីដាក់ទស្សនាទានពីយេនឌ័រ និងភាពងាយរងគ្រោះរួមបញ្ចូលគ្នា? | គោលបំណងរួម គឺដើម្បី**ធ្វើសមាហរណកម្មកិច្ចពិភាក្សានានាស្តីពីយេនឌ័រ និងភាពងាយរងគ្រោះ នៅក្នុងកិច្ចប្រជុំដែលបានគ្រោងទុក** ឲ្យកាន់តែមានអត្ថន័យ ដោយបន្ថែមពីលើការរៀបចំកិច្ចប្រជុំ/វេទិកាដាច់ដោយឡែក ដើម្បីដោះស្រាយបញ្ហាសង្គមនានា។ បទពិសោធន៍នានា បង្ហាញថា **កិច្ចប្រជុំដាច់ដោយឡែកទាំងនេះ** ចូលរួមជាចម្បងពីភាគីពាក់ព័ន្ធ ដែលរងគ្រោះពីការអភិវឌ្ឍ/ក្រុមតំណាងដែលរងគ្រោះ។ ដូច្នេះ វេទិកាដាច់ទាំងនេះ មានអត្ថប្រយោជន៍ខ្លាំងបំផុត ក្នុងការផ្តល់ជាកន្លែងសម្រាប់ការបញ្ចេញមតិយោបល់តាមមូលដ្ឋាន និងការប្រមូលព័ត៌មានពីបញ្ហាប្រឈម តម្រូវការ និងចំណុចខ្លាំងផ្សេងៗរបស់ក្រុមគោលដៅ។<br><br>ដើម្បីជំរុញការជជែកពិភាក្សាដោយពិចារណាពីយេនឌ័រ និងភាពងាយរងគ្រោះ និងផ្តោតលើតម្រូវការរួមសម្រាប់ទិន្នន័យតាមផ្នែកដែលត្រូវបានពង្រឹង ប៉ុន្តែវាក៏ចាំបាច់ផងដែរ ក្នុងការ**បង្កើតនូវបទដ្ឋានស្តីពីយេនឌ័រ និងភាពងាយរងគ្រោះសម្រាប់កិច្ចពិភាក្សា ការធ្វើបទបង្ហាញ និងការផ្លាស់ប្តូរយោបល់ផ្សេងៗ នៅក្នុងកម្មវិធីសម្រាប់ភាគីពាក់ព័ន្ធ ដែលមានដូចខាងក្រោមនេះ៖** |

| | | |
|---|---|---|
| | | ១. ទាក់ទងគ្នាជាមុន ដោយឯកភាពថាគ្រប់បទបង្ហាញ និងគម្រោងកិច្ចពិភាក្សា ត្រូវតែឆ្លើយតបនឹងសមាសធាតុផ្សេងៗនៃយេនឌ័រ និងភាពងាយរងគ្រោះ៖ តើយើងដឹងអ្វីខ្លះពីជនរងគ្រោះ ហើយនរណាខ្លះបានរួមចំណែក និងតាមវិធីណាខ្លះ?<br>២. ធានាថា អង្គការសង្គមស៊ីវិល និងអ្នកឯកទេសផ្សេងៗ ដែលសកម្មផ្នែកយេនឌ័រ និងភាពងាយរងគ្រោះ (ឧ. វិទ្យាស្ថានអប់រំដែលបានរៀបចំការសិក្សាស្រាវជ្រាវពីយេនឌ័រ និងភាពងាយរងគ្រោះ) អាចចូលរួមវេទិកា/កិច្ចប្រជុំនានា និងផ្តល់ជាទីតាំងសម្រាប់បញ្ចេញមតិយោបល់ (ជាតុចូល) របស់ពួកគេ នៅក្នុងកិច្ចពិភាក្សាបច្ចេកទេស។<br>៣. ប្រើប្រាស់កិច្ចប្រជុំភាគីពាក់ព័ន្ធ ពិភាក្សាពីគម្លាតទិន្នន័យយេនឌ័រ និងភាពងាយរងគ្រោះ និងជម្រើសនានា ដើម្បីដោះស្រាយបញ្ហាទាំងនេះ។<br><br>ភាពតំណាងដោយតុល្យភាពនៃភាគីពាក់ព័ន្ធជាច្រើនក្នុងវេទិកាទាំងនេះ នឹងមានសារៈសំខាន់ ក៏ដូចជាកំណត់ត្រាដោយសង្គតិភាព ការធ្វើរបាយការណ៍ និងនីតិវិធីតាមដានផលប៉ះពាល់នានា។ វាក៏ចាំបាច់ផងដែរ ក្នុងការលើកកម្ពស់ការយល់ដឹង និងផ្តល់ព័ត៌មានយ៉ាងទូលំទូលាយ ដោយប្រើប្រាស់ភាសាតាមមូលដ្ឋាន សម្រាប់ក្រុមសង្គមមួយចំនួន ដើម្បីឲ្យពួកគេអាចបញ្ចេញមតិយោបល់ដោយស្មើភាពគ្នា ក្នុងអំឡុងពេលចូលរួមវេទិកានានា។ |
| **សមាសភាគនៃក្រុមជំនាញចម្រុះសម្រាប់អាងទន្លេ** | តើសមាសធាតុយេនឌ័រ និងភាពងាយរងគ្រោះ អាចត្រូវបានដាក់បញ្ចូលជាប្រព័ន្ធនៅក្នុងកិច្ចប្រជុំ | **ការកំណត់អត្តសញ្ញាណមន្ត្រីជំនាញដែលមានបទពិសោធន៍ផ្នែកយេនឌ័រពីក្រសួងថ្នាក់ជាតិនានា។** មន្ត្រីទាំងនេះ អាចជាបុគ្គលិកបច្ចេកទេស ដែលមានបទពិសោធន៍ក្នុងការដាក់បញ្ចូលសមាសធាតុយេនឌ័រ និង |

| | | |
|---|---|---|
| | របស់ក្រុមមន្ត្រីជំនាញបានយ៉ាងដូចម្តេច? | ភាពងាយរងគ្រោះ ទៅក្នុងកិច្ចការរបស់គេ ឬក្រុមការងារឯកទេសផ្នែកយេនឌ័រពីក្រសួងតាមវិស័យនានា។ លើសពីក្រសួងទាំងនេះ មន្ត្រីជំនាញក៏អាចមានការចូលរួមពី**ស្ថាប័នជំនាញផ្នែកយេនឌ័រថ្នាក់ជាតិ** (ប្រទេសកម្ពុជាមានក្រសួងកិច្ចការនារី, ឡាវ និងវៀតណាមមានសហព័ន្ធស្ត្រី ឬគណៈកម្មការជាតិសម្រាប់លើកកម្ពស់ស្ត្រី, និងថៃមានគណៈកម្មការជាតិស្តីពីកិច្ចការនារី)។ ដៃគូនៅកម្រិតអាស៊ាន អាចជាគណៈកម្មការអាស៊ានស្តីពីការលើកកម្ពស់ និងគាំពារសិទ្ធិស្ត្រី និងកុមារ (ACWC) អង្គការហ្វាវ ជីអាយហ្សិតចំ និងអង្គការអន្តរជាតិអុកហ្វាម។<br><br>បន្ថែមពីនេះ **លក្ខខណ្ឌយោង**សម្រាប់មន្ត្រីឯកទេសគប្បីរួមបញ្ចូលនូវចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងយេនឌ័រ និងភាពងាយរងគ្រោះ រួមទាំងការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ។ ការផ្តោតជាចម្បងសម្រាប់មន្ត្រីជំនាញផ្នែកយេនឌ័រ និងភាពងាយរងគ្រោះ គួរផ្តោតលើការលើកកម្ពស់នៃការប្រមូលជាប្រព័ន្ធនូវទិន្នន័យតាមផ្នែក ការធ្វើសុខដុមនីយកម្ម និងសមាហរណកម្មសមាសធាតុយេនឌ័រ និងភាពងាយរងគ្រោះ នៅក្នុងការរៀបចំបង្កើតគម្រោងរួម ការរៀបចំផែនការជាដើម។ |
| **រៀបចំបង្កើតមូលនិធិទន្លេមេគង្គមួយ** | តើយើងអាចប្រើប្រាស់មូលនិធិផ្សេងៗ ដោយរបៀបណាខ្លះ ដើម្បីលើកកម្ពស់សមធម៌យេនឌ័រ និងកាត់បន្ថយភាពងាយរងគ្រោះ? | ពាក់ព័ន្ធនឹងយេនឌ័រ និងភាពងាយរងគ្រោះ ការរៀបចំបង្កើតមូលនិធិ ត្រូវធានាថា៖<br>ក) គម្រោងទទួលបានមូលនិធិទាំងអស់ រៀបចំធ្វើការវិភាគផ្នែកយេនឌ័រ និងភាពងាយរងគ្រោះ (ពីជនរងគ្រោះ និងរបៀបរងគ្រោះ) វាស់វែងពីផលប្រយោជន៍សម្រាប់ជនរងគ្រោះ និងរបៀបរងគ្រោះ និងដាក់បញ្ចូលនូវយន្តការគាំពារដោយគ្មានហានិភ័យ និងសមាសធាតុផ្សេងៗ ដើម្បីលើកកម្ពស់សមធម៌ ទៅតាមលទ្ធភាពដែលអាចមាន។ ឧទាហរណ៍មួយ គឺ |

| | | |
|---|---|---|
| | | សកម្មភាពឆ្លើយតបនឹងហានិភ័យដោយពិចារណាពីយេនឌ័រ។<br><br>ខ) ឱកាស និងដៃគូនានា ត្រូវបានកំណត់ដើម្បីលើកកម្ពស់ជាពិសេសនូវការផ្តល់អំណាចដល់ក្រុម/តំបន់ជាក់លាក់ ដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។ ឧ. គឺការលើកកម្ពស់នូវភាពជាអ្នកដឹកនាំស្ត្រីក្នុងគណៈកម្មាធិការតាមមូលដ្ឋាន ដើម្បីពង្រឹងការតាមដាន/ការធ្វើរបាយការណ៍ពីថ្នាក់មូលដ្ឋានទៅថ្នាក់ជាតិ សម្រាប់ព្យាករណ៍ដែលបានកែលម្អ និងការវាយតម្លៃផលប៉ះពាល់ ទាក់ទងនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។ |
| **ការប្រាស្រ័យទាក់ទង និងទំនាក់ទំនងសាធារណៈ** | តើយើងអាចបញ្ជ្រាបសមាសធាតុយេនឌ័រ និងភាពងាយរងគ្រោះទៅក្នុងការប្រាស្រ័យទាក់ទង និងទំនាក់ទំនងសាធារណៈឲ្យបានជាប្រចាំតាមវិធីណាខ្លះ? | ការអនុវត្តប្រសើរបំផុតក្នុងការបញ្ជ្រាបយេនឌ័រសម្រាប់ការប្រាស្រ័យទាក់ទង និងទំនាក់ទំនងសាធារណៈ មានដូចខាងក្រោមនេះ៖[23]<br><br>១. រួមបញ្ចូលគ្នានូវតួលេខតាមផ្នែក ដោយបង្ហាញពីភាពខុសៗគ្នាតាមស្ថានភាព/វិស័យសម្រាប់ស្ត្រី និងបុរស និងសមាសធាតុអន្តរវិស័យនានានៃវិសមភាពដែលគេជួបប្រទះ<br><br>២. ធានាឲ្យមានមិនត្រឹមតែភាពស្មើគ្នាប៉ុណ្ណោះទេ ប៉ុន្តែក៏មានភាពត្រឹមត្រូវជាក់ស្តែង (ឧ. ជៀសវាងការបង្ហាញពីកិច្ចការបែបផ្នត់គំនិត និងទំនាក់ទំនងអំណាចមិនស្មើភាពគ្នា) និងមានគោលបំណងធ្វើការបង្ហាញពីរូបភាពស្ត្រី និងបុរសនៅក្នុងតួនាទីចម្រុះដែលប្រឈមនឹងតួនាទីតាមយេនឌ័រ។ |

[23] សម្រាប់បុគ្គលិកផ្នែកទំនាក់ទំនងសាធារណៈ វាមានសារៈប្រយោជន៍នឹងមើលអត្ថបទពីការប្រើប្រាស់ភាសាដែលមានបរិយាបន្នយេនឌ័ររបស់អង្គការសហប្រជាជាតិ ក៏ដូចជាការអនុវត្តប្រសើរនានាលើបញ្ហានេះ (Marin,២០១៨)។

៣. ធានាថា វិភាគទានរបស់ស្ត្រី និងបុរសលើសកម្មភាព/វិស័យនានា ត្រូវបានបង្ហាញដោយយុត្តិធម៌ និងទៅតាមជាក់ស្តែង ត្ួយ៉ាងកិច្ចការថែទាំដោយគ្មានប្រាក់កម្រៃពីស្ត្រីតាមតំបន់ជនបទ៖ កង្វះការចូលរួមរបស់ស្ត្រីក្នុងសេដ្ឋកិច្ចថវិកា មិនបានបង្ហាញថា កិច្ចការទាំងនេះ មិនបានរួមចំណែកក្នុងសេដ្ឋកិច្ចនោះទេ ផ្ទុយមកវិញ កិច្ចការដែលគេមើលមិនឃើញទាំងនេះ ជួយធ្វើឲ្យសមាជិកគ្រួសាររបស់គេ បានចូលរួមក្នុងកម្លាំងពលកម្ម។

៤. ប្រើប្រាស់ភាសាឆ្លើយតបនឹងយេនឌ័រ នៅក្នុងការបោះពុម្ពផ្សាយ៖ ប្រើពាក្យ ‘ស្ត្រី’ និង ‘កុមារី’ ជាជាងពាក្យ ‘ភេទស្រី’, និងពាក្យ ‘បុរស’ និង‘កុមារា’ ជាជាង ‘ភេទប្រុស’ ដោយហេតុថា ពាក្យ‘ភេទស្រី’ និង‘ប្រុស’ កំណត់ពីភាពខុសគ្នាបែបជីវសាស្ត្រនៅក្នុងវិស័យឱសថសាស្ត្រ និងជីវវិទ្យា ខណៈដែលពាក្យ ‘ស្ត្រី’ និង‘បុរស’ កំណត់ពីមនុស្សជាតិ ហេតុដូច្នេះ វាបង្ហាញពីភាពជាមនុស្ស។ ការប្រើប្រាស់ពាក្យ ‘ភេទស្រី និង‘ប្រុស ដើម្បីពណ៌នាស្ត្រី និងបុរស បានបន្ថយន័យរបស់វាមកត្រឹមតែសមត្ថភាពបន្តពូជ និងធ្វើឲ្យភាពខុសគ្នារវាងស្ត្រី និងបុរស មានកម្រិតកាន់តែខ្លាំង ដោយសារបញ្ហាជីវវិទ្យា ជាជាងតួនាទីដែលបង្កើតឡើងដោយសង្គម។ ឧ. ប្រើប្រាស់ ‘កសិករស្ត្រី’ ជាជាង ‘កសិករភេទស្រី’ ។

បន្ថែមពីនេះ បើអាចអនុវត្តបាន ប្រើគោរមងារមុខងារដោយបរិយាបន្នយេនឌ័រ នៅតាមកម្មវិធី ក្នុងកំណត់ត្រាកិច្ចប្រជុំជា

| | | |
|---|---|---|
| | | ដើម តួយ៉ាងពាក្យ 'បុគ្គលជាប្រធាន' ជាជាង 'ប្រធាន(ប្រុស)'។[24]<br><br>៥. ជៀសវាងការបង្កើតការរើសអើងបន្ថែមទៀតក្នុងការប្រើប្រាស់ភាសា និងឯកសាររូបភាព ឧ. មិនមែន 'ប្រជាជនងាយរងគ្រោះ'ទេ ប៉ុន្តែជា 'ប្រជាជនស្ថិតក្នុងស្ថានភាពងាយរងគ្រោះ', បង្ហាញថាស្ត្រី និងបុរសជាអ្នកចូលរួម/ទីភ្នាក់ងារជំរុញ ជាជាងអ្នកទទួលប្រយោជន៍ដោយអកម្ម។ |

## ការពង្រឹងការបញ្ជ្រាប (យេនឌ័រ និងភាពងាយរងគ្រោះ) តាមស្ថាប័នរបស់ MRC

ជំពូកនេះ រំលេចពីសមាសភាគស្ថាប័នផ្សេងៗ និងនីតិវិធីផ្ទៃក្នុងនានា ដែលចាំបាច់សម្រាប់បញ្ជ្រាបចំណេះដឹងផ្នែកយេនឌ័រ និងភាពងាយរងគ្រោះ និងការប្រើប្រាស់នៅក្នុងស្ថាប័នទាំងមូល។[25]

| **ទិដ្ឋភាពស្ថាប័ន** | **តម្រូវការនានាសម្រាប់ការបញ្ជ្រាប** |
|---|---|
| **ការលើកកម្ពស់គណនេយ្យភាពសម្រាប់ការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះ** | គណនេយ្យភាព សំដៅលើគោលបំណង និងអាទិភាពនានារបស់ស្ថាប័នមួយ ក៏ដូចជាបទប្បញ្ញត្តិ និងនីតិវិធីនានា។ ការបញ្ជ្រាបយេនឌ័រគឺជាយុទ្ធសាស្ត្រដែលអនុវត្តពីកម្រិតថ្នាក់គ្រប់គ្រង ដល់ថ្នាក់រដ្ឋបាល តួយ៉ាងចាប់ពី 'ថ្នាក់ដឹកនាំជាន់ខ្ពស់'នៃស្ថាប័នមួយ ដែលទទួលបន្ទុកក្នុងការបង្កើតឲ្យមានគណនេយ្យភាពសម្រាប់ការអនុវត្តរបស់វា។<br><br>គណនេយ្យភាព អាចនឹងសម្រេចបានតាម៖<br><br>ក) **យន្តការផ្លូវការ** (អាណត្តិរបស់ MRC បទប្បញ្ញត្តិនីតិវិធី និងការពណ៌នាការងារ ដែលដាក់បញ្ចូលសមាសធាតុផ្សេងៗផ្នែកយេនឌ័រ និងភាពងាយរងគ្រោះ)<br><br>ខ) **យន្តការក្រៅផ្លូវការ** (វិធីដែលថ្នាក់គ្រប់គ្រងដោះស្រាយបញ្ហាយេនឌ័រ និងភាពងាយរងគ្រោះនៅក្នុងកិច្ចប្រជុំនានា និងរបៀបដាក់បញ្ចូលបញ្ហាទាំងនេះក្នុងរបៀបវារៈប្រជុំ |

[24] សម្រាប់ការណែនាំពីការប្រើប្រាស់ភាសាដោយបរិយាបន្នដែលមានប្រយោជន៍ សូមមើលគោលការណ៍ណែនាំនានារបស់អង្គការសហប្រជាជាតិសម្រាប់ការប្រើប្រាស់ភាសាដែលមានបរិយាបន្នយេនឌ័រ (Marin,២០១៨)។

[25] ជំពូកនេះ បានព័ត៌មានមកពីការសិក្សាស្រាវជ្រាវរបស់ EIGE ស្តីពីការផ្លាស់ប្តូរស្ថាប័ន (EIGE,២០១៦ក)។

| | |
|---|---|
| | ហើយបន្ថែមពីនេះ ការចាត់ចែងកិច្ចការយ៉ាងច្បាស់លាស់ និងការទទួលខុសពាក់ព័ន្ធ ឲ្យដល់សមាជិកបុគ្គលិក យោងទៅតាមផែនការសកម្មភាពស្ដីពីយេនឌ័រ និងលើសពីនេះ)។ |
| **ការបែងចែកធនធាន** | **ធនធានហិរញ្ញវត្ថុ/ការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ៖** សកម្មភាពនានា ក្នុងផែនការសកម្មភាពស្តីពីយេនឌ័រ ត្រូវតែមានខ្សែបណ្តាយថវិកា រួមទាំងសកម្មភាពបណ្តុះបណ្តាលសមត្ថភាពដែលអាចមានសម្រាប់បុគ្គលិក។<br><br>**ធនធានមនុស្ស៖** ធានាថា សកម្មភាពបញ្ជ្រាបយេនឌ័រ (ឧ. ប្រព័ន្ធជូនដំណឹងជាមុន) ត្រូវបានរៀបចំតាមវេលាជាក់លាក់នៅក្នុងផែនការការងារសម្រាប់បុគ្គលិក/នាយកដ្ឋាន (ផ្នែក)។ វាមានហានិភ័យដែលថា កិច្ចការបញ្ជ្រាបនេះ ត្រូវបានគេមើលឃើញថាជាផ្នែកមួយនៃការងារជាប្រចាំ ជាហេតុ វានឹងក្លាយជាកិច្ចការ 'អាទិភាព' ឬបន្ថែម ដែលងាយស្រួលនឹងបោះបង់ចោល។ ជាការពិត ការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះ ទាមទារឲ្យមានការវិភាគ ការធ្វើសមាហរណកម្ម និងការពិនិត្យតាមដាន ដូច្នេះ គេត្រូវរៀបចំពេលវេលា ឲ្យស្របទៅតាមកិច្ចការទាំងនេះ។ |
| **ការរៀបចំការវិភាគពីយេនឌ័រ និងភាពងាយរងគ្រោះតាមស្ថាប័ន ឲ្យក្លាយជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍ស្ថាប័នសម្រាប់ MRC** | ការវិភាគបែបស្ថាប័ន គប្បីផ្តោតលើសមាសធាតុចំនួនពីរ៖<br><br>ក) ការត្រួតពិនិត្យឡើងវិញនូវសមាសភាគនៃបុគ្គលិកលេខាធិការដ្ឋាន ទាក់ទិននឹងសន្ទស្សន៍យេនឌ័រ សមធម៌ និងភាពចម្រុះនៅទូទាំងស្ថាប័ន MRC ទាំងមូល និងនៅគ្រប់កម្រិតគ្រប់គ្រងផ្សេងៗគ្នា នឹងផ្តល់ជាព័ត៌មានពីគោលបំណងនៃភាពចម្រុះ និងសមធម៌សម្រាប់ផែនការអភិវឌ្ឍន៍ស្ថាប័ន។ ការអនុវត្តធនធានមនុស្ស ក្នុងការជ្រើសរើស និងការវាយតម្លៃសមិទ្ធកម្មកិច្ចការដោយពិចារណាលើយេនឌ័រ និងស្ថានភាពទាក់ទងនឹងប្រាក់កម្រៃដោយស្មើភាពគ្នា គប្បីត្រូវបានគេវិភាគ។ ផែនការបរមាណភាព (កូតា) និងការណែនាំរៀនសូត្រ អាចនឹងត្រូវបានប្រើប្រាស់ធ្វើការលើកកម្ពស់សន្ទស្សន៍ ជាពិសេសនៅក្នុងតួនាទីដឹកនាំ។ វាមានគោលបំណងជំរុញឲ្យមានវប្បធម៌តាមស្ថាប័ន ដែលមានភាពស្មើគ្នា ចម្រុះភាព តម្លាភាព និងដោយពិចារណាលើយេន |

| | |
|---|---|
| | ឆ័រ។<br><br>ខ) ការវាយតម្លៃសមត្ថភាពនៃជំនាញយេនឌ័ររបស់បុគ្គលិក និងតម្រូវការរៀងៗខ្លួន។ លទ្ធផលនៃការវាយតម្លៃបែបចូលរួម គប្បីរួមបញ្ចូលនូវទិដ្ឋភាពរួមមួយនៃចំណុចខ្លាំង និង ចំណុចខ្សោយរបស់បុគ្គលិក និងនាយកដ្ឋានផ្សេងៗនៃ លេខាធិការដ្ឋាន MRC ក្នុងការបញ្ជ្រាបយេនឌ័រ និងភាព ងាយរងគ្រោះ ព្រមទាំងអនុសាសន៍នានា ពីចំណុចចាប់ផ្តើម និងវិធីក្នុងការពង្រឹងរចនាសម្ព័ន្ធ និងសមត្ថភាពបុគ្គលិកឲ្យ បានសមស្រប។ តំបន់មុខងារដែលត្រូវត្រួតពិនិត្យឡើងវិញ គប្បីផ្តោតលើរចនាសម្ព័ន្ធស្ថាប័ន (ឧ. តាមឋានានុក្រម នីតិ វិធីនានា) បុគ្គលិក (ឧ. ចំណេះដឹងផ្នែកយេនឌ័រ និងភាព ងាយរងគ្រោះ ឥរិយាបទ ការប្រព្រឹត្តក្រៅផ្លូវការ និងតំបន់ កិច្ចការរបស់ MRC និងលទ្ធផលរបស់កិច្ចការទាំងនេះ។ |
| **ការរៀបចំជាផ្លូវការនូវរចនាសម្ព័ន្ធគាំពារផ្ទៃក្នុងផ្នែកយេនឌ័រ និងភាពងាយរងគ្រោះ** | នៅពេលមន្ត្រីដែលមានឱកាសស្មើគ្នា ផ្តោតលើការទទួលបានឱកាស ដោយស្មើភាពគ្នា សម្រាប់បុគ្គលិកក្នុងស្ថាប័ន រចនាសម្ព័ន្ធគាំពារការ បញ្ជ្រាបយេនឌ័រ មានតួនាទីជួយសម្រួលការផ្លាស់ប្តូរតាមស្ថាប័ន ទាក់ទងនឹងមុខងារ និងលទ្ធផលរបស់ស្ថាប័ន។ អាស្រ័យហេតុនេះ **តួនាទីនៃមន្ត្រីដែលមានឱកាសស្មើគ្នា** មិនគួររួមបញ្ចូលជាមួយនឹង **រចនាសម្ព័ន្ធគាំពារការបញ្ជ្រាបយេនឌ័រ**ឡើយ។ ទោះបីជា MRC ប្តេជ្ញាចិត្តបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះ នៅតាមគ្រប់នាយកដ្ឋាន ទៅតាមកិច្ចការបច្ចេកទេសក៏ដោយ ក៏គេគួរតែធ្វើការកំណត់ពីតួនាទីគាំពារជាក់លាក់ផងដែរ។ វាមិនចាំបាច់ ទាមទារឲ្យជ្រើសរើសបុគ្គលិកថ្មីនោះទេ ប៉ុន្តែវាស្នើឲ្យមានការបែងចែកកិច្ចការឲ្យបានច្បាស់លាស់ សម្រាប់ និង*ជាពិសេស* ក្រុមជំនាញកិច្ចការយេនឌ័រ និង បុគ្គលិកធនធានមនុស្ស រួមទាំងការគាំទ្ររបស់ថ្នាក់គ្រប់គ្រង សម្រាប់ការលើកកម្ពស់ការបញ្ជ្រាបផ្នែកយេនឌ័រ។ គេតែងតែផ្តល់ជាសំណើរ ឲ្យដាក់កិច្ចការបញ្ជ្រាបយេនឌ័រទៅក្នុងការពណ៌នាការងារ និង លក្ខខណ្ឌយោងរបស់បុគ្គលិកនីមួយៗ ដើម្បីកុំឲ្យកិច្ចការផ្នែកយេនឌ័រក្លាយទៅជា‘កិច្ចការបន្ថែម’។ |
| ការអភិវឌ្ឍបទដ្ឋានយេនឌ័រ និង ភាពងាយរងគ្រោះសម្រាប់ការ | **អភិវឌ្ឍ ឬត្រួតពិនិត្យឡើងវិញនូវបទដ្ឋានទំនាក់ទំនងផ្ទៃក្នុង និងផ្ទៃក្រៅនានា៖** |

| | |
|---|---|
| **ប្រាស្រ័យទាក់ទង** | **ផ្ទៃក្នុង៖** ធានាថា បុគ្គលិកទាំងអស់យល់ដឹងពីកិច្ចការរួមនៃការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះ និងពីការតាំងចិត្តដោយសមធម៌របស់ MRC។ វាមិនមែនជាការប្រាស្រ័យទាក់ទងដែលកើតមានឡើងតែម្តង ឬមួយពេលទេ ប៉ុន្តែគេគប្បីធ្វើការកំណត់បណ្តាញទំនាក់ទំនងខុសៗគ្នា សំដៅផ្តោតខ្លាំងលើខ្លឹមសារទាំងនេះឲ្យបានទៀងទាត់។<br><br>**ផ្ទៃក្រៅ៖** រំលេចពីការលើកកម្ពស់នៃសមភាពយេនឌ័រ ជាគោលដៅអាទិភាពមួយក្នុងចំណោមគោលដៅអាទិភាពជាច្រើនរបស់ MRC (គេហទំព័រ ការបោះពុម្ពផ្សាយ កម្មវិធីនានា)។ ត្រួតពិនិត្យឡើងវិញនូវការបោះពុម្ពផ្សាយ និងឯកសារទំនាក់ទំនងសាធារណៈ សម្រាប់ការប្រើប្រាស់ភាសា និងរូបភាពដោយពិចារណាលើយេនឌ័រ។<br><br>ផ្តល់លទ្ធភាពឲ្យបុគ្គលិកផ្នែកប្រាស្រ័យទាក់ទង និងទំនាក់ទំនងសាធារណៈ អភិវឌ្ឍជំនាញពាក់ព័ន្ធរបស់ពួកគេ តាមរយៈការបណ្តុះបណ្តាល។ |
| **ការពង្រឹងជំនាញយេនឌ័ររបស់បុគ្គលិក** | បទពិសោធន៍ បង្ហាញថាផលវិបាកនៃយន្តការនានា ដូចជាការបណ្តុះបណ្តាលពីសមភាពយេនឌ័រ អាចបាត់បង់យ៉ាងរហ័ស បើវាមានភាពចម្រុះត្រឹមតែមួយពេល ឬបើវាជំនួសឲ្យត្រឹមតែយន្តការសម្រាប់ការណែនាំការបញ្ជ្រាបយេនឌ័រ។<br><br>សមត្ថភាពសមភាពយេនឌ័រ រួមមានការប្តេជ្ញាចិត្ត ជំនាញគរុកោសល្យ និងចំណេះដឹងឯកទេស៖<br><br>• **ការប្តេជ្ញាចិត្ត** សំដៅលើការទទួលស្គាល់នូវសមភាពយេនឌ័រជាគោលបំណងទាំងរបស់ស្ថាប័ន និងការងារផ្ទាល់ខ្លួន។ វារួមមានការទទួលបន្ទុកក្នុងការអនុវត្តការបញ្ជ្រាបយេនឌ័រនៅក្នុងតំបន់ការងារផ្ទាល់ខ្លួននៃប្រតិបត្តិការនានា។ ការតាំងចិត្តរបស់ស្ថាប័នចំពោះ និងការលើកទឹកចិត្តបុគ្គលិកសម្រាប់ការបញ្ជ្រាបយេនឌ័រ ជាចម្បងត្រូវបានជំរុញដោយការប្រព្រឹត្តនិងឧទាហរណ៍ល្អរបស់ថ្នាក់គ្រប់គ្រង។<br><br>• **ជំនាញគរុកោសល្យ** សំដៅលើសមត្ថភាពអនុវត្តការបញ្ជ្រាបយេនឌ័រ ដោយប្រើប្រាស់វិធីសាស្រ្ត និងឧបករណ៍សមស្រប |

| | |
|---|---|
| | ដូចដែលបានផ្តល់ជូននៅក្នុងជំនួយកិច្ចការនេះ។ វាក៏រួមបញ្ចូលនូវសមត្ថភាពធ្វើការកំណត់អត្តសញ្ញាណ និងទទួលទិន្នន័យតាមយេនឌ័រដែលត្រូវការ និងប្រើប្រាស់ទិន្នន័យនេះក្នុងកិច្ចការផ្ទាល់ខ្លួន។ ដោយហេតុថា ផែនការសកម្មភាពស្តីពីយេនឌ័រនាពេលបច្ចុប្បន្ន ផ្តោតជាចម្បងលើការប្រមូលទិន្នន័យដែលបានពង្រឹង វាមានភាពចាំបាច់ជាពិសេសក្នុងការបង្កើតយុទ្ធសាស្ត្រជាប្រព័ន្ធនានា ដើម្បីប្រើប្រាស់ព័ត៌មានដែលទទួលបានស្តីពីសមាសធាតុពាក់ព័ន្ធយេនឌ័រ និងភាពងាយរងគ្រោះ នៅក្នុងការរៀបចំគម្រោង និងការអនុវត្តសកម្មភាពរបស់ MRC។<br><br>• **ចំណេះដឹងឯកទេស** រួមបញ្ចូលទាំងការយល់ដឹងផ្នែកទ្រឹស្តីនៃយេនឌ័រ ជាទ្រង់ទ្រាយសង្គម ហើយចំណេះដឹងស៊ីជម្រៅពីទំនាក់ទំនងយេនឌ័រ ជារចនាសម្ព័ន្ធសង្គម។ វាក៏គ្របដណ្តប់លើចំណេះដឹងស្រាវជ្រាវជាក់ស្តែងពីសមាសធាតុយេនឌ័រនៅក្នុងតំបន់គោលនយោបាយ និងសកម្មភាពនានារបស់ស្ថាប័ន ក៏ដូចជាសមត្ថភាពក្នុងការចាត់ចំណាត់ថ្នាក់ និងបកស្រាយការពិត និងទិន្នន័យតាមយេនឌ័រឲ្យបានត្រឹមត្រូវ។ ខណៈដែលគេមិនរំពឹងថា បុគ្គលិកគ្រប់រូបនឹងក្លាយជាអ្នកឯកទេសផ្នែកយេនឌ័រ គេគប្បីផ្តោតលើការដាក់បញ្ចូលសមត្ថភាពយេនឌ័រ ទៅក្នុងគោលដៅអភិវឌ្ឍន៍ជំនាញបុគ្គលិកវិញ។<br><br>បទដ្ឋានស្ថាប័នមួយ ត្រូវបានរៀបចំឡើងភាគច្រើន ដើម្បីប្រគល់តួនាទីឲ្យអង្គភាពគ្រប់គ្រងធនធានមនុស្ស រៀបចំបង្កើត ដឹកនាំ និងតាមដានផែនការអភិវឌ្ឍន៍សមត្ថភាពផ្នែកសមភាពយេនឌ័រសម្រាប់បុគ្គលិក។[26] ក៏ប៉ុន្តែ គេនៅតែលើកជាសំណើរឲ្យមានការសហការជិតស្និទ្ធរវាងកិច្ចការគ្រប់គ្រង ជាមួយនឹងរចនាសម្ព័ន្ធគាំពារការបញ្ជ្រាបយេនឌ័រ ដើម្បីធានាឲ្យមានទំនាក់ទំនងបច្ចេកទេសយ៉ាងជិតស្និទ្ធ។ |
| **ប្រព័ន្ធគ្រប់គ្រងព័ត៌មានយេនឌ័រ និងការតាមដានផែនការ** | ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីយេនឌ័របច្ចុប្បន្នរបស់ MRC ផ្តល់សារៈសំខាន់ខ្លាំងលើការប្រមូលទិន្នន័យពាក់ព័ន្ធនឹង |

[26] សម្រាប់សំណួរណែនាំដ៏មានប្រយោជន៍ និងការអនុវត្តប្រសើរនានាសម្រាប់ការអភិវឌ្ឍផែនការបណ្តុះបណ្តាលសមត្ថភាពផ្នែកយេនឌ័រ សូមមើល EIGE (២០១៦ក) ស្តីពីការអភិវឌ្ឍជំនាញសមភាពយេនឌ័រ។

| | |
|---|---|
| **សកម្មភាពស្ដីពីយេនឌ័រ** | យេនឌ័រ និងភាពងាយរងគ្រោះ។ ដូច្នេះ វាមានភាពចាំបាច់ណាស់ក្នុងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មានយេនឌ័រ ដែលគេរំពឹងថា បរិមាណទិន្នន័យ និងព័ត៌មានទាំងនេះនឹងកើនឡើង។<br><br>ការពិចារណាសំខាន់ៗ សម្រេចឲ្យបាននូវគោលដៅនេះ រួមមាន៖<br><br>ក) តើយើងអាចធ្វើឲ្យប្រសើរឡើងនូវការប្រមូលទិន្នន័យតាមផ្នែកនៅកម្រិតថ្នាក់ជាតិ និងថ្នាក់តំបន់បានដោយរបៀបណា?<br>ខ) តើនរណាជាអ្នកធ្វើដំណើរការទិន្នន័យ និងព័ត៌មានដែលទទួលបានទាំងនេះ និងតាមរបៀបណា?<br>គ) តើយើងអាចចែកចាយចំណេះដឹងដែលទទួលបាន ឲ្យមានប្រសិទ្ធភាពដោយរបៀបណា និងទៅឲ្យនរណា?<br><br>ម៉្យាង MRC មានបំណងបញ្ជ្រាបកិច្ចការទាំងអស់របស់ខ្លួន ដើម្បីដាក់បញ្ចូលទិន្នន័យឲ្យមានន័យទៅក្នុងដំណើរការរៀបចំផែនការ នីតិវិធី គោលការណ៍ណែនាំជាដើម។ ម៉្យាងវិញទៀត វានៅតែត្រូវការជានាថា ព័ត៌មានយេនឌ័រមានរួចជាស្រេច ដើម្បីទទួល និងប្រើប្រាស់ទៅវិញទៅមក ទាំងនៅក្នុងស្ថាប័ន និងសម្រាប់ភាគីពាក់ព័ន្ធនានា។<br><br>ខណៈដែលអង្គភាពបច្ចេកទេស នឹងទទួលបន្ទុកជាចម្បងក្នុងការប្រមូលទិន្នន័យយេនឌ័រ និងភាពងាយរងគ្រោះ អាស្រ័យទៅតាមផែនការយុទ្ធសាស្ត្រ/ផែនការសកម្មភាពស្ដីពីយេនឌ័រ រចនាសម្ព័ន្ធគាំពារការបញ្ជ្រាបយេនឌ័រដែលបានកំណត់ គប្បីទទួលបន្ទុកត្រួតពិនិត្យគុណភាពនៃខ្លឹមសារ ការធ្វើបច្ចុប្បន្នភាពជាប្រចាំ និងបទបង្ហាញរួមប្រកបដោយតម្លាភាព។ ការរៀបចំបង្កើតប្រព័ន្ធព័ត៌មានស្ដីពីយេនឌ័រ គប្បីអនុវត្តនៅក្នុង (ឬកៀកនឹង) ប្រព័ន្ធតាមដានជាប្រចាំរបស់ MRC។ មួយផ្នែក គេគួរពិចារណាបង្កើតរចនាសម្ព័ន្ធមួយ ដែលអាចវាយតម្លៃដោយភាគីពាក់ព័ន្ធខាងក្រៅបាន ដើម្បីជាជំនួយដល់គោលដៅរបស់ MRC ក្នុងការប្រមូលទិន្នន័យដោយសុខដុមនីយកម្ម និងបង្កើតមូលដ្ឋានព័ត៌មានកាន់តែទូលំទូលាយ ក្នុងចំណោមភាគីពាក់ព័ន្ធតាមដងទន្លេ។ ផែនការសកម្មភាពស្ដីពីយេនឌ័រ ត្រូវតែដាក់បញ្ចូលទៅក្នុងប្រព័ន្ធតាមដាន និងវាយតម្លៃជាប្រចាំរបស់ MRC រួម |

| | |
|---|---|
| | ទាំងអនុគោលដៅ/ព្រឹត្តិការណ៍សំខាន់បន្ថែមទៀត ដែលបានកំណត់នៅក្នុងឯកសារផែនការសកម្មភាពស្តីពីយេនឌ័រ។<br><br>ដើម្បីធ្វើឲ្យគេមើលឃើញព័ត៌មានថ្មីៗជាបន្តបន្ទាប់ បុគ្គលិកគាំពារការបញ្ជ្រាបយេនឌ័រ គប្បីមានគោលបំណងចែករំលែកចំណេះដឹង ឬបច្ចុប្បន្នភាពនានា ទៅឲ្យស្ថាប័នទាំងមូល (ឬស្ថាប័នផ្សេងៗ) ឲ្យបានទៀងទាត់ តួយ៉ាងតាមរយៈព្រឹត្តិប័ត្រព័ត៌មាន និងកិច្ចប្រជុំបច្ចុប្បន្នភាពពីយេនឌ័រ និងភាពងាយរងគ្រោះដែលបានគ្រោងទុកនៅក្នុងកិច្ចប្រជុំរបស់បុគ្គលិក។ |
| **ឯកសារយុទ្ធសាស្ត្រ/ណែនាំពីការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះតាមស្ថាប័ន** | សមាសធាតុខុសៗគ្នានៃការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះត្រូវបានគេស្នើឲ្យចងក្រងជាឯកសារយុទ្ធសាស្ត្រមួយ ឬសំណុំឯកសារស្តីពីយេនឌ័រ និងភាពងាយរងគ្រោះដែលបានចងក្រង ដែលបុគ្គលិក និងមន្ត្រីជំនាញគាំពារអាចប្រើប្រាស់បាន។ ឯកសារយុទ្ធសាស្ត្រ/ណែនាំនេះ គួររួមបញ្ចូលនូវ៖<br><br>• ទិដ្ឋភាពរួមមួយ ស្តីពីកន្លែង និងវិធីដែលរចនាសម្ព័ន្ធស្ថាប័នជួយគាំទ្រដល់ការបញ្ជ្រាបយេនឌ័រ និងភាពងាយរងគ្រោះ និងការលើកកម្ពស់ឲ្យមានឱកាសស្មើៗគ្នា<br>• សេចក្តីសង្ខេបមួយនៃគោលដៅសមភាពស្ថាប័នរបស់ MRC<br>• ការដាក់បញ្ជ្រាបបទដ្ឋានទំនាក់ទំនងដោយពិចារណាពីយេនឌ័រ នៅក្នុងផែនការទំនាក់ទំនងប្រចាំឆ្នាំរបស់ MRC<br>• ផែនការអភិវឌ្ឍន៍បុគ្គលិក (ការលើកកម្ពស់ជំនាញយេនឌ័រ)<br>• ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់យេនឌ័រ៖ កន្លែង និងរបៀបបង្កើតព័ត៌មានយេនឌ័រ និងរបៀបប្រើប្រាស់ទិន្នន័យទាំងនេះ<br>• ព័ត៌មានពីវិធី (និងអនុវត្តដោយនរណា) តាមដាន និងជំរុញគោលដៅសមភាព និងសកម្មភាពសម្រាប់ផែនការសកម្មភាពស្តីពីយេនឌ័រ<br>• ផែនការសកម្មភាពស្តីពីយេនឌ័រមួយ និងឧបសម្ព័ន្ធជំនួយការងារ |

# ឯកសារយោង និងឯកសារណែនាំ

## ការសិក្សាស្រាវជ្រាវពីយេនឌ័រ


ASEAN. (2011). *Socio-cultural community blueprint 2025*. Jakarta: The ASEAN Secretariat. https://bit.ly/3BeWV7E

EIGE. (2020a). Intersectional discrimination. Accessed 20 June 2020. https://eige.europa.eu/thesaurus/terms/1492

EIGE. (2020b). What is gender mainstreaming. Accessed 20 June 2020. https://bit.ly/3iKFCFi

EU. (2016). Intersectional discrimination in EU gender equality and non-discrimination law. Luxembourg: Publications Office of the European Union. https://op.europa.eu/s/xh5n

Gender Spectrum. (2019). Understanding gender. Accessed 20 June 2020. https://genderspectrum.org/articles/understanding-gender

GWP. (1996). Dublin-Rio principles. Accessed on 25 June 2020. https://gwptoolbox.org/resource/dublin-rio-principles

IUCN. (2018). Gender equality and women's empowerment policy: Mainstreaming gender-responsiveness within the IUCN programme of work. Accessed 25 June 2020. https://bit.ly/3BgBblv

MRC. (2013). *Commitment on gender mainstreaming in water resources development in the Lower Mekong Basin*. Vientiane: MRC Secretariat. https://doi.org/10.52107/mrc.ajgsg0

ONS. (2019). What is the difference between sex and gender? https://bit.ly/3h3DvMh

United Nations Department of Economic and Social Affairs. (n.d.). Sustainable development: Make the SDGs a reality. https://sdgs.un.org

UNSTATS. (2015). Gender statistics manual: What are gender statistics? https://unstats.un.org/unsd/genderstatmanual/What-are-gender-stats.ashx

UNFPA. (2005). Frequently asked questions about gender equality. Accessed 25 June 2020. https://bit.ly/3FbYcNW

SGV. (2019). Gender equality: What is it and why do we need it? Accessed 26 June 2020. https://bit.ly/3HgRGYQ

WHO. (2020). Gender and health. Accessed 26 June 2020. https://bit.ly/3h7IECQ

WHO Europe. (2020). Gender. Access 26 June 2020. https://bit.ly/3iLClVZ


## ការបញ្ជ្រាបយេនឌ័រ៖ ឧបករណ៍ និងការអនុវត្តល្អៗ


Brown, S., Budimir, M., Sneddon, A., Lau, D., Shakya, P., & Crawford, S. U. (2019). Gender transformative early warning systems: Experiences from Nepal and Peru. Rugby,

United Kingdom: Practical Action.
https://bit.ly/3h1ZeUX
EIGE. (2016a). Economic benefits of gender equality in the European Union. Literature review – existing evidence and methodological approaches. Vilnius: EIGE.
https://bit.ly/3P75UNW

EIGE. (2016b). Institutional transformation: Gender mainstreaming toolkit. Vilnius: Publications Office of the European Union.
https://bit.ly/3iKh2nV
OECD. (2015). *Stakeholder engagement for inclusive water governance (OECD Studies on Water)*. Paris: OECD Publishing.
http://dx.doi.org/10.1787/9789264231122-en
Ferrant, G. & Kolev, A. (2016). The economic cost of gender-based discrimination in social institutions. OECD Development Centre. Accessed 26 June 2020.
https://bit.ly/3iCWAVT
Marin, F. (2018). Let´s speak gender: 10 principles of gender-responsive communications for development. United Nations Development Programme. Accessed 26 June 2020.
https://bit.ly/3VTbSnS
UNISDR, UNDP, & IUCN. (2009). *Making disaster risk reduction gender-sensitive: Policy and practical guidelines*. Geneva: United Nations International Strategy for Disaster Reduction.
https://bit.ly/3VByZ6P
UN. (n.d.). Toolbox for using gender-inclusive language in English. Accessed 26 June 2020.
www.un.org/en/gender-inclusive-language/toolbox.shtml
UN. (n.d.). Guidelines for gender-inclusive language in English. Accessed 26 June 2020.
www.un.org/en/gender-inclusive-language/guidelines.shtml
Wodon, Q. T., & de la Brière, B. (2018). *Unrealized potential: The high cost of gender inequality in earnings*. Washington, DC: World Bank.
https://openknowledge.worldbank.org/handle/10986/29865
WHO. (2014). *Gender, climate change and health*. Geneva: World Health Organization.
https://bit.ly/3UDMHo8

## ឯកសារណែនាំ

### ការអនុវត្តដ៏ប្រសើរ និងបទពិសោធន៍មេរៀនដែលទទួលបានពីអង្គការឧតុនិយមសកលលោកស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ និងការអនុវត្តនានារបស់ស្ថាប័ន៖

WMO. (2020). Mainstreaming gender in organizational policies and practices. Accessed 20 June 2020. https://bit.ly/3F7BI0v

### ការដោះស្រាយបញ្ហាប្រឆាំងតបនឹងការបញ្ជ្រាបយេនឌ័រ (ពីបុគ្គល ស្ថាប័ន និងនៅកម្រិតជជែកពិភាក្សា)៖

EIGE. (2016b). Institutional transformation: Gender mainstreaming toolkit. Vilnius: Publications Office of the European Union. https://bit.ly/3iKh2nV

## គោលការណ៍ណែនាំស្ដីពីការបញ្ជ្រាបយេនឌ័រសម្រាប់អង្គការអាងទន្លេប្រចាំភាគខាងត្បូងអាហ្វ្រិក

(ឯកសារនេះ បានផ្តល់ជាព័ត៌មានសម្រាប់មាតិការចនាសម្ព័ន្ធខ្លះៗនៃសៀវភៅនេះ)

SADC. (2015). Guidelines for strengthening river basin organizations: Mainstreaming gender in RBOs in SADC. Gaborone, Botswana: Southern African River Basin Organizations.

## អភិបាលកិច្ចទឹក និងយេនឌ័រ៖ ការសិក្សាមួយស្ដីពីជីវប្រវត្តិនៃសមាជិកគណៈកម្មាធិការអន្តររដ្ឋាភិបាលអាងទន្លេក្នុងប្រទេសប្រេស៊ីល

(ការសិក្សាស្រាវជ្រាវនេះ ផ្តល់នូវបទពិសោធន៍មេរៀនដ៏មានតម្លៃពីការធ្វើឲ្យប្រសើរឡើងនូវបរិយាបន្នក្នុងភាពតាងនៃក្រុមខុសៗគ្នាក្នុងគណៈកម្មាធិការអភិបាលកិច្ចទឹក)

Matos, F., Camargo, E., & de Padua Carrieri, P. (2021). Water governance and gender: A study on the profile of members of river basin interstate committees in Brazil. Belo Horizonte: FACE/UFMG.

## ពីទិន្នន័យយេនឌ័រ និងតម្រូវការបែងចែកទិន្នន័យលើសពីភេទបែបជីវសាស្ត្រ៖

Valero, S. D. (2019). Why are gender statistics important? https://bit.ly/3UEDfkD

**Mekong River Commission Secretariat**

P. O. Box 6101, 184 Fa Ngoum Road, Unit 18 Ban Sithane Neua,
Sikhottabong District, Vientiane 01000, Lao PDR
Tel: +856 21 263 263. Fax: +856 21 263 264
www.mrcmekong.org

© Mekong River Commission 2022